# សេចក្តីណែនាំជាគោលនយោបាយ
# ស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ




## សេចក្តីណែនាំដំបូងសម្រាប់
## អ្នកសាងគោលនយោបាយ
## និងអ្នកអនុវត្ត

The Bali Process

នីតិវិធីក្រុងបាលីស្តីអំពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស ហើយនិងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធ( នីតិវិធីក្រុងបាលី ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០២ និងជាកម្មវិធីពិគ្រោះយោបល់ក្នុងតំបន់ដែលធ្វើឡើងដោយការស្ម័គ្រចិត្តនិងមិនមានចំណងហើយនិងមានរដ្ឋាភិបាលអូស្ត្រាលីនិងឥណ្ឌូណេស៊ីជាសហប្រធាន និងប្រទេសនិងអង្គការ៤៥ជាសមាជិក។

ចំពោះសំនួរទាំងឡាយទាក់ទងនឹងសេចក្តីណែនាំជាគោលនយោបាយនេះ សូមបញ្ជូនទៅ ការិយាល័យជំនួយការប្រចាំដំបន់ ( RSO ) សម្រាប់នីតិវិធីក្រុងបាលី តាមអ៊ីម៉េល info@rso.baliprocess.net
គេហទំព័ររបស់ RSO:
http://www.baliprocess.net/regional-support-office

បោះពុម្ពនៅខែឧសភា ឆ្នាំ ២០១៥

# អ្នករួមចំណែកចងក្រង

សេចក្តីណែនាំជាគោលនយោបាយនេះ បានសាងឡើងដោយសមាជិកនៃនីតិវិធីក្រុងបាលី គាំទ្រដោយការិយាល័យជំនួយការប្រចាំដំបន់ ហើយនិងដឹកនាំដោយគណៈកម្មាធិការព្រាងសេចក្តីណែនាំជាគោលនយោបាយនៃនីតិវិធីក្រុងបាលី មានសមាជិកដូចតទៅ ៖

**ឡាលូ មុហាម៉ាត់ អ៊ីកបាល់ (Lalu Muhamad Iqbal)**
នាយកស្តីទី នៃនាយកដ្ឋានការពារប្រជាពលរដ្ឋឥណ្ឌូនេស៊ីនិងនីតិបុគ្គល
ក្រសួងការបរទេស ប្រទេសឥណ្ឌូនេស៊ី (សហប្រធាន)

**ចណាធិន ម៉ាចិនស៍ (Jonathan Martens)**
ប្រធានអង្គភាពជំនួយទេសន្តរជន ការិយាល័យប្រចាំតំបន់សម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក អង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) (សហប្រធាន)

**មីហ្គិន ឆាលមើរស៍ (Megan Chalmers)**
មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្នែកឧក្រិដ្ឋកម្មប្រឆាំងមនុស្ស
មហាអយ្យការ ប្រទេសអូស្ត្រាលី

**ម៉ូហាម៉ិត ស៊ីហ្វាន (Mohamed Shifan)**
អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍
ក្រសួងអន្តោប្រវេសន៍និងកិច្ចការចំណាកស្រុក
ប្រទេសមលឌីវស៍

**រ៉ប៊ើត ឡាហ្គា (Robert Larga)**
ប្រធាននាយកដ្ឋានអាជ្ញាប័ណ្ណនិងនីយ័ត្តកម្ម
កិច្ចការរដ្ឋបាលនៃការងារបរទេសហ្វីលីពីន
ប្រទេសហ្វីលីពីន

**ពិនធិប លីឡាគ្រៀងសាក់ ស្រ៊ីសានិត**
**(Pinthip Leelakriangsak Srisanit)**
ព្រះរាជអាជ្ញា នាយកដ្ឋានកិច្ចការអន្តរជាតិ
មហាអយ្យការ ប្រទេសថៃឡង់

ជំនួយបន្ថែមចំពោះគណៈកម្មាធិការព្រាងឯកសារ ផ្តល់ដោយ:
**ធិម ហាវ (Tim Howe)**
អ្នកសម្របសម្រួលគំរោងការ IOM ការិយាល័យជំនួយការប្រចាំតំបន់

The Bali **Process**

# អារម្ភកថា

ចាប់តាំងពីកកើតនាឆ្នាំ២០០២មក នីតិវិធីក្រុងបាលីស្តីអំពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធ (ហៅកាត់ថា នីតិវិធីក្រុងបាលី) បានធ្វើឲ្យមានការយល់ដឹងនៅក្នុងតំបន់អំពីផលវិបាកនៃការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលពាក់ព័ន្ធ ហើយនិងបានបង្កើតនិងអនុវត្តយុទ្ធសាស្ត្រនិងសហប្រតិបត្តការដើម្បីឆ្លើយតប។ មានប្រទេសជាសមាជិកនិងអង្គការអន្តរជាតិទាំងអស់៤៨ បូកនិងប្រទេសនិងអង្គការអន្តរជាតិក្នុងឋានៈជាអ្នកសង្កេតផង ក៏បានចូលរួមក្នុងវេទិកាដោយស្ម័គ្រចិត្តនេះ។

មន្ត្រីជាន់ខ្ពស់នៅក្នុងកិច្ចប្រជុំលើកទី៨នៃក្រុមអាដហុកក្នុងនីតិវិធីក្រុងបាលី បានស្នើឲ្យការិយាល័យជំនួយការប្រចាំតំបន់នៃនីតិវិធីក្រុងបាលី (Bali Process Regional Support Office) ហៅកាត់ថា RSO បង្កើតសេចក្តីណែនាំមួយចំនួនជាគោលនយោបាយស្តីអំពីបញ្ហាសំគាល់និងការពារជនដែលត្រូវគេជួញដូរ ដោយពិគ្រោះយោបល់ជាមួយនឹងសមាជិកទាំងឡាយណាដែលមានផលប្រយោជន៍ពាក់ព័ន្ធ។ បន្ទាប់ពីមានទិសដៅនេះហើយ RSO បានបង្កើតគណៈកម្មាធិការព្រាងឯកសារមួយដែលមានឥណ្ឌូណេស៊ីនិង IOM ធ្វើសហប្រធានដើម្បីព្រាងសេចក្តីណែនាំជាគោលនយោបាយទាំងនោះ។ គណៈកម្មាធិការព្រាងឯកសារមានអ្នកជំនាញចេញពីរដ្ឋាភិបាលនៃប្រទេសឥណ្ឌូណេស៊ី អូស្ត្រាលី មលឌីវស៍ ហ្វីលីពីន ថៃឡង់ ហើយនិង IOM។

គណៈកម្មាធិការបានជួបជុំគ្នាបួនដងក្នុងរយៈពេល៦ខែ ក្នុងគោលបំណងបង្កើតសេចក្តីណែនាំខ្លីដំបូងសម្រាប់អ្នកសាងគោលនយោបាយនិងអ្នកអនុវត្ត ស្តីអំពីបញ្ហាពាក់ព័ន្ធនឹងការសំគាល់ហើយនិងការការពារជនរងគ្រោះពីការជួញដូរ។ សេចក្តីព្រាងនៃសេចក្តីណែនាំទាំងឡាយនោះត្រូវបានចែកចាយជូនទៅសមាជិកព្រមទាំងអ្នកសង្កេតការណ៍នៃនីតិវិធីក្រុងបាលី ដើម្បីគេអាចផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ហើយនិងសម្រាប់ពិភាក្សានិងពិនិត្យឡើងវិញនៅសិក្ខាសាលាពេញអង្គ នាថ្ងៃ ២៣-២៤ មិនា ឆ្នាំ២០១៥នៅទីក្រុងបាងកកប្រទេសថៃ។ អ្នកចូលរួមទាំងឡាយបានឯកភាពថាសេចក្តីណែនាំជាគោលនយោបាយទាំងនោះជាធនធានមានប្រយោជន៍សម្រាប់អ្នកសាងគោលនយោបាយនិងអ្នកអនុវត្តក្នុងការជួយសំគាល់និងការពារជនរងគ្រោះពីការជួញដូរ។ ឆ្លើយតបទៅនឹងយោបល់ទទួលបានពីសមាជិក គណៈកម្មាធិការព្រាងសេចក្តីបានពិនិត្យសើរើសេចក្តីព្រាងទាំងឡាយនោះដោយមានបញ្ចូលនូវការកែតម្រូវសំខាន់ៗនិងយោបល់ទាំងនោះផង។

សេចក្តីណែនាំជាគោលនយោបាយទាំងឡាយនោះមានបំណងបង្ហាញទិទ្ធភាពរួមនៃស្តង់ដាថ្នាក់អន្តរជាតិនិងតំបន់សម្រាប់សំគាល់និងការពារជនរងគ្រោះពីការជួញដូរ ដោយទាញយកគំរូល្អៗជាច្រើនពីបទពិសោធន៍របស់ប្រទេសជាសមាជិកនៃនីតិវិធីក្រុងបាលី។ ស្របតាមអនុសាសន៍របស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៥នាខែមិនាឆ្នាំ២០១៣ សេចក្តីណែនាំជាគោលនយោបាយទាំងឡាយនោះជាជុំទី២នៃសេចក្តីណែនាំជាគោលនយោបាយរបស់នីតិវិធីក្រុងបាលី ហើយដែលស្ថិតក្នុងវង្វង់សាច់រឿងរបស់នីតិវិធីក្រុងបាលីស្តីអំពីបញ្ហានានាដែលសមាជិកនៃនីតិវិធីក្រុងបាលីមានបារម្ភ។ សេចក្តីណែនាំទាំងនោះសម្រាប់ប្រើដោយស្ម័គ្រចិត្ត ពុំមានចំណង ហើយនិងបំពេញបំណងជាឯកសារសម្រាប់ពិគ្រោះរបស់ភ្នាក់ងារទាំងឡាយក្នុងស្រុករបស់រដ្ឋជាសមាជិកនៃនីតិវិធីក្រុងបាលី។

**លីសា ក្រហ្វើត (Lisa Crawford)**
សហប្រធាន RSO (អូស្ត្រាលី)

**ប៊ិប៊ិប អេខេអិន ជុនជូណាន (Bebeb A.K.N. Djundjunan)**
សហប្រធាន RSO (ឥណ្ឌូណេស៊ី)

# អក្សរកាត់

| | |
|---|---|
| **អាស៊ាន** | សមាគមនៃប្រជាជាតិអាស៊ីអគ្នេយ៍ |
| **នីតិវិធីក្រុងបាលី** | នីតិវិធីក្រុងបាលីស្តីអំពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលពាក់ព័ន្ធ |
| **ILO** | អង្គការពលកម្មអន្តរជាតិ |
| **IOM** | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ |
| **អនុសញ្ញាឧក្រិដ្ឋកម្មរៀបចំ** | អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ |
| **RSO** | ការិយាល័យគាំទ្រប្រចាំតំបន់នៃនីតិវិធីក្រុងបាលី |
| **ពិធីការនៃការជួញដូរមនុស្ស** | ពិធីការទប់ស្កាត់ សង្កត់និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមទៅលើពិធីការអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លង ដែនរៀបចំ |
| **UNHCR** | ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន |
| **UNODC** | ការិយាល័យអង្គការសហប្រជាជាតិសម្រាប់គ្រឿងញៀននិងឧក្រិដ្ឋកម្ម |

# មាតិការឿង


សេចក្ដីសង្ខេប **2**

ផ្នែកទី១: សេចក្ដីផ្ដើមអំពីការការពារជនរងគ្រោះពីការជួញដូរ **3**

១.១. ក្របខ័ណ្ឌច្បាប់អន្តរជាតិសម្រាប់ការពារជនរងគ្រោះពីការជួញដូរ 3

១.២. ឧបសគ្គក្នុងការការពារ 5

១.៣. ការពិចារណាក្នុងការការពារ : កាតព្វកិច្ចសំខាន់ៗនិងផលប្រយោជន៍ 6

ផ្នែកទី២: ការអនុវត្តការការពារ **8**

២.១. ការការពារដំបូង 8

២.២. ការការពារតាមរយៈនីតិវិធីរកយុត្តិធម៌ក្នុងបទព្រហ្មទ័ណ្ឌ 10

២.៣. ដំណោះស្រាយការការពារប្រកបដោយចីរភាព 14

ផ្នែកទី៣: ការសម្របសម្រួលនិងបែបបទពហុអង្គភាព **17**

៣.១. អ្នកទទួលបន្ទុកទាំងឡាយនៃការការពារ 17

៣.២. ការសម្របសម្រួលថ្នាក់នយោបាយ 19

៣.៣. ការសម្របសម្រួលថ្នាក់ប្រតិបត្ត 20

ផ្នែកទី៤: ការប្រមូលផ្ដុំតម្រុយសម្រាប់ការពារជនរងគ្រោះពីការជួញដូរ **22**

# សេចក្តីសង្ខេប

ការជួញដូរមនុស្សជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិមនុស្ស។ រដ្ឋទាំងឡាយមានកាតព្វកិច្ចការពារជនរងគ្រោះដែលជាផ្នែកមួយនៃកាតព្វកិច្ចអន្តរជាតិក្រោម ពិធីការដើម្បីទប់ស្កាត់ សង្កត់ និងដាក់ទោសការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ (ពិធីការជួញដូរមនុស្ស) ហើយនិងឯកសារច្បាប់ឯទៀតៗរួមទាំងអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស និងការប្តេជ្ញាក្នុងដំបន់។ ការការពារជនរងគ្រោះក៏ជាកត្តាដ៏ចំបងមួយក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធិភាពតាមរយៈវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម គឺលុះណាតែជនរងគ្រោះត្រូវបានគេការពារត្រឹមត្រូវសមស្រប ទើបជនរងគ្រោះទាំងនោះមានកម្លាំងគាំទ្រកម្មវិធីរកយុត្តិធម៌ប្រឆាំងនឹងអ្នកជួញដូរ។

ក្នុងការបំពេញកាតព្វកិច្ចដែលត្រូវធ្វើចំពោះជនរងគ្រោះ សេចក្តីណែនាំជាគោលនយោបាយនេះស្នើឲ្យរដ្ឋនានាប្រើវិធីដែលដាក់ជនរងគ្រោះនៅកណ្តាល គឺគិតអំពីសេចក្តីត្រូវការរបស់ជនរងគ្រោះ ហើយផ្តល់ការការពារសមស្របជាចម្លើយទៅតាមស្ថានភាពជាក់ស្តែង។ មិនគួរយកការចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មជាលក្ខ័ណ្ឌដើម្បីផ្តល់ការការពារដល់ជនរងគ្រោះឬក៏កាត់បន្ថយការការពារឡើយ។ អាជ្ញាធរនានារបស់រដ្ឋត្រូវទទួលបានការគាំទ្រក្នុងការងាររបស់គេ គឺធ្វើឲ្យគេយល់អំពីបញ្ហាទាំងឡាយក្នុងការការពារ និងទទួលការហាត់រៀនឲ្យចេះដោះស្រាយបញ្ហាទាំងនោះប្រកបដោយប្រសិទ្ធិភាពតាមក្របខ័ណ្ឌច្បាប់និងបែបបទអនុវត្តអន្តរជាតិសមស្រប។

ដើម្បីប្រតិបត្តតាមកាតព្វកិច្ចក្នុងការការពារ រដ្ឋគួរការពារជនរងគ្រោះពីការជួញដូរកុំឲ្យទទួលគ្រោះថ្នាក់បន្ថែមទៀតចាប់តាំងពីពេលជួបគ្នាដំបូងរហូតដល់ពេលដែលជននោះមានកំរិតជីវភាពសង្គមនិងសេដ្ឋកិច្ចល្អមឲ្យគេរស់នៅដោយខ្លួនឯងបាន។ ក្នុងកម្មវិធីការពារដំបូង គួរមានការដោះស្រាយអំពីសេចក្តីត្រូវការរបស់គេដែលបន្ទាន់ហើយនិងផ្តល់ឱកាសសម្រាប់គេគិតពិចារណាដើម្បីឲ្យគេចាប់ផ្តើមសះស្បើយឡើងវិញទាំងផ្លូវកាយទាំងផ្លូវចិត្ត ហើយនិងធ្វើការសម្រេចអំពីអនាគតរបស់គេ រួមទាំងការចូលរួមឬមិនចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មដែលគេបានឆ្លងកាត់។ ចំពោះអ្នកដែលស្ម័គ្រចិត្តចូលរួមជាទម្លាប់ល្អ នៅគ្រប់ដំណាក់នៃកម្មវិធី គួរផ្តល់លទ្ធភាពឲ្យជនរងគ្រោះបញ្ចេញទស្សនៈនិងសេចក្តីបារម្ភរបស់គេ ហើយអាជ្ញាធរគួរពិចារណានិងដោះស្រាយ។ ដោយសារការគម្រាមដល់ជនរងគ្រោះមានការផ្លាស់ប្តូរជានិច្ច ផែនការនៃការការពារគួរមានការពិនិត្យសើរើផ្អែកទៅលើហានិភ័យដែលឃើញមាន។

ដំណោះស្រាយក្នុងវិស័យការពារដែលប្រកបដោយប្រសិទ្ធិភាពនិងចីរភាពអាចជួយជនរងគ្រោះឲ្យមានជីវភាពគ្រប់គ្រាន់និងអាចរួមរស់ក្នុងសង្គមឡើងវិញបាន។ សេចក្តីណែនាំនេះគូសឲ្យឃើញច្បាស់ថាលទ្ធភាពក្នុងការទទួលសំណងតាមរយៈកម្មវិធីបណ្តឹងព្រហ្មទ័ណ្ឌឬរដ្ឋប្បវេណីជាកត្តាសំខាន់មួយក្នុងការធ្វើឲ្យជនរងគ្រោះសះស្បើយឡើងវិញនិងរួមរស់ក្នុងសង្គមវិញ។ ជនរងគ្រោះពីការជួញដូរឆ្លងដែនអាចត្រឡប់ទៅប្រទេសដើមខ្លួនវិញ បន្តរស់នៅក្នុងប្រទេសដែលគេបានរកឃើញ ឬក៏ទៅប្រទេសណាផ្សេងមួយទៀត បន្ទាប់ពីចំណាយពេលពិចារណាអំពីអ្វីៗដែលខ្លួនបានឆ្លងកាត់និងបានសះស្បើយឡើងវិញ ឬក៏ក្រោយពីបណ្តឹងប្រឆាំងនឹងអ្នកជួញដូរដំណើរការចប់សព្វគ្រប់ហើយ។ ក្នុងការគិតថាជម្រើសណាមួយជាការប្រសើរជាងគេសម្រាប់ជនរងគ្រោះ គេត្រូវគិតផងដែរអំពីការគំរាមសងសឹកនិងការបំភិតបំភ័យនានាមកលើជនរងគ្រោះ។

ទោះបីកាតព្វកិច្ចក្នុងការការពារជនរងគ្រោះស្ថិតនៅលើរដ្ឋ ភាគីដទៃក៏អាចដើរតួសំខាន់ក្នុងការគាំទ្ររដ្ឋក្នុងការបំពេញកាតព្វកិច្ចទាំងនោះដែរ។ ដូច្នេះការសម្របសម្រួលរវាងនិងក្នុងចំណោមរដ្ឋនិងអង្គភាពមិនមែនរដ្ឋជាការសំខាន់ជាទីបំផុត។ អង្គភាពមិនមែនរដ្ឋអាចមានជំនាញក្នុងការធ្វើឲ្យជនរងគ្រោះទុកចិត្តនិងមានទំនាក់ទំនងល្អជាមួយនឹងគ្នា អាចយល់អំពីសេចក្តីត្រូវការរបស់ជនរងគ្រោះ ហើយអាចផ្តល់សេវាប្រកបដោយប្រសិទ្ធិភាពនិងពេញលក្ខណៈក្នុងការដោះស្រាយបញ្ហាទាំងនោះ។ ដើម្បីឲ្យការការពារមានប្រសិទ្ធិភាពខ្ពស់ អាចត្រូវការការសហការរវាងរដ្ឋនិងរដ្ឋ។ យន្តការរឹងមាំទ្វេភាគីនិងការសហការក្នុងដំបន់ដែលសព្វថ្ងៃមានក្នុងដំបន់អាស៊ីប៉ាស៊ីហ្វិកស្រាប់ រួមទាំងនីតិវិធីក្រុងបាលីផង ជាមូលដ្ឋានដ៏រឹងមាំក្នុងការពង្រឹងសហប្រតិបត្តការក្នុងវិស័យការពារ។ សេចក្តីណែនាំជាគោលនយោបាយនេះ ដាក់ជូនសម្រាប់ជាឧបករណ៍គាំទ្ររដ្ឋនានាក្នុងកិច្ចការយ៉ាងសំខាន់ក្នុងការកសាងកម្មវិធីការពារទាំងឡាយហើយនិងធ្វើឲ្យមានស្តង់ដានៅក្នុងដំបន់។

# ផ្នែកទី១:

## សេចក្តីផ្តើមនៃការការពារជនរងគ្រោះពីការជួញដូរ

### ១.១. ក្របខ័ណ្ឌច្បាប់អន្តរជាតិក្នុងការការពារជនរងគ្រោះ

ប្រការ២៥ របស់*អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ* (អនុសញ្ញាឧក្រិដ្ឋកម្មរៀបចំ) តម្រូវឲ្យភាគីរដ្ឋនានាផ្តល់ជំនួយនិងការការពារដល់ជនរងគ្រោះ ជាពិសេសក្នុងករណីមានការគំរាមថាមានការសងសឹកឬការបំភិតបំភ័យ ហើយនិងការបង្កើតកម្មវិធីនានាសម្រាប់ផ្តល់លទ្ធភាពដល់ជនរងគ្រោះក្នុងការទទួលសំណងចំពោះការខូចខាត។ ការការពារជនរងគ្រោះជាគោលបំណងមួយរបស់ *ពិធីការទប់ស្កាត់ សង្កត់និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ* (ពិធីការនៃការជួញដូរមនុស្ស) ដែលបន្ថែមទៅលើអនុសញ្ញាឧក្រិដ្ឋកម្មរៀបចំ។ ប្រការ៦ របស់ពិធីការនៃការជួញដូរមនុស្សចែងថារដ្ឋទាំងឡាយ :

- ក្នុងករណីសមស្របនិងដែលអាចធ្វើបាន ត្រូវរក្សាពត៌មាននិងអត្តសញ្ញាណរបស់ជនរងគ្រោះ ព្រមទាំងបណ្តឹងនានាឲ្យស្ថិតនៅសម្ងាត់
- ក្នុងករណីសមស្រប ត្រូវផ្តល់ដល់ជនរងគ្រោះនូវពត៌មានអំពីបណ្តឹងតុលាការនិងរដ្ឋបាល និងជួយជនរងគ្រោះក្នុងការបង្ហាញទស្សនៈនិងថ្លែងអំពីក្តីបារម្ភរបស់គេក្នុងការកាត់សេចក្តីរបស់តុលាការក្នុងអាកប្បកិរិយាដែលមិនបង្កភាពអយុត្តិធម៌ដល់ភាគីចុងចោទ(ប្រការ៦(២))
- ត្រូវផ្តល់ជំនួយដែលធ្វើឲ្យជនរងគ្រោះបានស្បើយមកវិញអំពីការរងទុក្ខផ្លូវកាយ ផ្លូវចិត្តនិងសង្គម តាមមធ្យោបាយដែលរួមទាំងការផ្តល់កន្លែងស្នាក់នៅសមស្រប ការពិគ្រោះនិងផ្តល់យោបល់ ជំនួយក្នុងវិស័យពេទ្យនិងជម្ងឺផ្លូវចិត្តនិងជាវត្ថុ ហើយនិងផ្តល់ឱកាសការងារ សិក្សា និងការហាត់រៀននានា (ប្រការ៦(៣))។
- ត្រូវខំធ្វើយ៉ាងណាឲ្យជនរងគ្រោះមានសុវត្ថិភាព (ប្រការ៦(៥))។
- ត្រូវធ្វើយ៉ាងណាឲ្យប្រព័ន្ធយុត្តិធម៌ផ្តល់លទ្ធភាពឲ្យជនរងគ្រោះទទួលបានសំណងចំពោះការខូចខាត (ប្រការ៦(៦))។

*ពិធីការនៃការជួញដូរមនុស្ស* *ក៏សង្កត់ធ្ងន់ថារដ្ឋគួរគិតអំពីអាយុ* ភេទ និងសេចក្តីត្រូវការរបស់ជនរងគ្រោះម្នាក់ៗ ជាពិសេសសេចក្តីត្រូវការរបស់កុមារ ដូចជាកន្លែងស្នាក់នៅ ការសិក្សា និងការថែទាំសមស្រប (ប្រការ៦(៤))។

### តម្រុយ: ធ្វើតាមគោលការណ៍សំខាន់ៗសម្រាប់ការពារជនរងគ្រោះពីការជួញដូរ

- មិនគួរឃុំឃាំង ចោទ ឬផ្តន្ទាទោស ចំពោះការចូលក្នុងរដ្ឋឬការត្រឡប់ចូលក្នុងរដ្ឋដោយមិនប្រក្រដី ឬការប្រព្រឹត្តល្មើសច្បាប់ឯទៀតៗដែលជាលទ្ធផលផ្ទាល់អំពីការដែលគេត្រូវបានគេជួញដូរ។
- មិនគួរឃុំឃាំង ចោទប្រកាន់ ឬផ្តន្ទាទោស ចំពោះការចូលក្នុងរដ្ឋឬការត្រឡប់ចូលក្នុងរដ្ឋដោយមិនប្រក្រ
- ជនរងគ្រោះគួរមានលទ្ធភាពទទួលការមើលថែផ្លូវកាយនិងផ្លូវចិត្តគ្រប់គ្រាន់។
- ជនរងគ្រោះគួរទទួលបាននូវជំនួយផ្លូវច្បាប់និងជំនួយផ្សេងៗទៀតក្នុងកម្មវិធីបណ្តឹងព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬប្រភេទផ្សេងទៀត។
- ជនរងគ្រោះពីការជួញដូរជាកុមារគួរទទួលបាននូវជំនួយនិងការការពារសមស្របយោងតាមភាពងាយរងគ្រោះ សិទ្ធិនិងសេចក្តីត្រូវការពិសេសរបស់គេ។
- ជនរងគ្រោះគួរទទួលបានការធានាពីរដ្ឋដែលទទួលយកឬរដ្ឋដើម អំពីសុវត្ថិភាពក្នុងការវិលទៅរដ្ឋនោះ (បើអាចបាន ធ្វើដោយស្ម័គ្រចិត្ត)។
- ជនរងគ្រោះគួរមានលទ្ធភាពទទួលបានកម្មវិធីបកទោសប្រកបដោយប្រសិទ្ធិភាពនិងសមស្រប។

*សូមមើលគោលការណ៍និងសេចក្តីណែនាំអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្សដែលជាអនុសាសន៍របស់ការិយាល័យអគ្គស្នងការសិទ្ធិមនុស្ស។*

គេត្រូវយល់មាត្រាចែងក្នុង ពិធីការនៃការជួញដូរមនុស្ស ក្នុងបរិបទធំទូលាយនៃក្របខ័ណ្ឌអន្តរជាតិសម្រាប់ផ្ដល់ជំនួយនិងការការពារដល់ជនរងគ្រោះពីការជួញដូរ។ យោងតាមប្រការ១៤(១) គេត្រូវមើលឲ្យយល់ ពិធីការ នេះយោងតាមច្បាប់អន្តរជាតិរួមទាំងច្បាប់អន្តរជាតិស្ដីពីសិទ្ធិមនុស្សនិងអំពីមនុស្សធម៌។

អនុសញ្ញាទាក់ទងនឹងឋានៈជនភៀសខ្លួន នាឆ្នាំ១៩៥១ និងពិធីការទាក់ទងនឹងឋានៈជនភៀសខ្លួន នាឆ្នាំ១៩៦៧ ហើយនិងគោលការណ៍នៃ ការមិនគាបសង្កត់ ត្រូវបានប្រើយោងដើម្បីបញ្ជាក់ថារដ្ឋពុំអាចបណ្ដេញចេញឬបញ្ជូនត្រឡប់ជនភៀសខ្លួនឬជនសុំសិទ្ធិជ្រកកោនទៅកន្លែងណាមួយដែលធ្វើឲ្យជីវិតឬសេរីភាពរបស់គេនោះមានការគំរាមដោយសារកត្តាជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពក្នុងក្រុមមួយ ឬគំនិតនយោបាយមួយ។ 1 ថែមពីលើនេះទៀត ប្រការ ១៤(២) នៃពិធីការនៃការជួញដូរមនុស្ស ពន្យល់ថាវិធានការណ៍នានាប្រកាន់យកក្នុងការអនុវត្តត្រូវគោរពតាមគោលការណ៍អន្តរជាតិស្ដីអំពីការមិនរើសអើង មានន័យថាគេមិនអាចរើសអើងមនុស្សដោយសារលក្ខណៈសម្បត្តិណាមួយឡើយ រួមទាំងឋានៈទេសន្តរប្រវេសន៍ ឬឋានៈអ្វីផ្សេងទៀតរបស់ជននោះ។

## តម្រុយ: ដាក់អនុវត្តមាត្រាស្ដីអំពីការការពារចែងក្នុងច្បាប់អន្តរជាតិ

រដ្ឋនានាគួរធ្វើតាមគំរូរបស់រដ្ឋមួយចំនួនដែលធ្វើលើសពីស្តង់ដាអប្បបរមាកំណត់ដោយពិធីការនៃការជួញដូរមនុស្ស ឧទាហរណ៍ ការបញ្ចូលកម្មវិធីផ្ដល់សំណងចំពោះការខូចខាតបន្ថែមទៅលើនិងនៅក្រៅកម្មវិធីបណ្ដឹងព្រហ្មទ័ណ្ឌ។និងនៅក្រៅកម្មវិធីបណ្ដឹងព្រហ្មទ័ណ្ឌ។

**ប្រកាន់ជំហរ "គ្មានការគាបសង្កត់" ក្នុងការការពារជនរងគ្រោះពីការជួញដូរ**

កាតព្វកិច្ចរបស់រដ្ឋក្នុងការមិនបញ្ជូនមនុស្សទៅដែនដីដែលមានហានិភ័យអាចធ្វើឲ្យជីវិតឬសេរីភាពរបស់គេត្រូវបានគំរាម ឬជននោះត្រូវគេសម្លាប់ ត្រូវអនុវត្តសម្រាប់មនុស្សគ្រប់រូប ហើយជះឥទ្ធិពលដល់ការការពារជនរងគ្រោះពីការជួញដូរផងដែរ។2 ជាពិសេសទាក់ទងនឹងកុមារ គណៈកម្មាធិការសិទ្ធិកុមារបានកំណត់ថា "ការត្រឡប់ទៅប្រទេសកំណើតវិញមិនមែនជាជម្រើសទេបើសិនវាអាចនាំឲ្យមានហានិភ័យសមល្មមដែលលទ្ធផលធ្វើឲ្យមានការបំពានលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់កុមារ និងជាពិសេសបើគោលការណ៍'គ្មានការគាបសង្កត់' (non-refoulement) ត្រូវនឹងស្ថានការណ៍នោះ។ ការត្រឡប់ទៅប្រទេសដើមវិញ ជាគោលការណ៍ ត្រូវធ្វើតែក្នុងករណីដែលធ្វើទៅមានប្រយោជន៍ដល់កុមារនោះ។"3

ទាក់ទងនឹងជនរងគ្រោះពីការជួញដូរជាកុមារ ប្រការ៣៩ របស់អនុសញ្ញាអំពីសិទ្ធិរបស់កុមារ បង្ខំឲ្យរដ្ឋយកចិត្តទុកដាក់អំពីការធ្វើឲ្យបានជាឡើងវិញទាំងផ្លូវកាយទាំងផ្លូវចិត្តហើយនិងការរួមរស់ក្នុងសង្គមរបស់ជនរងគ្រោះ។ ប្រការ៣ របស់អនុសញ្ញាអំពីសិទ្ធិរបស់កុមារ បង្ខំឲ្យរដ្ឋនានាគិតអំពីផលប្រយោជន៍ខ្ពស់បំផុតរបស់កុមារក្នុងគ្រប់វិស័យទាក់ទងនឹងកុមារ។ ការគិតអំពីផលប្រយោជន៍របស់កុមារគួរដាក់បញ្ចូលជាផ្លូវការក្នុងបែបបទនិងសេចក្ដីណែនាំនានាក្នុងការជួយនិងការការពារជនរងគ្រោះពីការជួញដូរជាកុមារ។ ពេលណាជនរងគ្រោះត្

---

[1] មើលប្រការ៣៣(១) នៃអនុសញ្ញាជនភៀសខ្លួនទាក់ទងនឹងឋានៈនៃជនភៀសខ្លួន (Refugee Convention relating to the Status of Refugees,ប្រការ៣ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (the Convention against Torture) ឆ្នាំ១៩៥១ និងប្រការ១៦ នៃអនុសញ្ញាអន្តរជាតិសម្រាប់ការការពារគ្រប់ជនពីការធ្វើឲ្យបាត់ខ្លួនដោយបង្ខិតបង្ខំ (International Convention for the Protection of All Persons from Enforced Disappearance.) ។ ចូរមើលផងដែរ ប្រការ៧ នៃច្បាប់អន្តរជាតិស្ដីអំពីសិទ្ធិរដ្ឋប្បវេណីនិងសិទ្ធិនយោបាយ (International Covenant on Civil and Political Rights) ដែលគណៈកម្មាធិការសម្រាប់សិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានបកស្រាយថាមានតម្រូវឲ្យមានការហាមឃាត់ refoulement (ការគាបសង្កត់)។ សូមមើល គណៈកម្មាធិការសម្រាប់សិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (HRC), CCPR យោបល់ជាទូទៅទី២០ ប្រការ៧នៃការហាមឃាត់ការធ្វើទារុណកម្ម ឬទង្វើកាចសាហាវ អមនុស្សធម៌ និងមាក់ងាយ ឬការដាក់ទោសពៃ (Prohibition of Torture, or Other Cruel, Inhuman or Degrading Treatment or Punishment), ចុះថ្ងៃទី ១០ មិនា ១៩៩២ កថាខ័ណ្ឌ ៩។

[2] អនុសញ្ញាជនភៀសខ្លួនទាក់ទងនឹងឋានៈនៃជនភៀសខ្លួន (Refugee Convention relating to the Status of Refugees) ឆ្នាំ១៩៥១ ប្រការ៣៣(១)។ ចូរមើលផងដែរពិធីការនៃការជួញដូរមនុស្ស (Trafficking in Persons Protocol) ប្រការ១៤ និងច្បាប់អន្តរជាតិស្ដីអំពីសិទ្ធិរដ្ឋប្បវេណីនិងសិទ្ធិនយោបាយ (International Covenant on Civil and Political Rights) ចុះថ្ងៃទី១៦ ធ្នូ ឆ្នាំ១៩៦៦ ប្រការ៦និង៧។ គោលការណ៍នៃការមិនគាបសង្កត់ (non-refoulement) ក៏បានទៅជាបន្ទាត់ច្បាប់នៃច្បាប់សាមញ្ញអន្តរជាតិ។

[3] គណៈកម្មាធិការសម្រាប់សិទ្ធិកុមារ យោបល់ទូទៅទី៦, (២០០៥), ទង្វើទៅលើកុមារដែលគ្មានមនុស្សធំនៅជាមួយនិងដែលបែកពីគេនៅក្រៅប្រទេសដើមរបស់ខ្លួន (*Treatment of unaccompanied and separated children outside their country of origin)* កថាខ័ណ្ឌ៨៤។ រដ្ឋគួរធ្វើយ៉ាងណាឲ្យអាជ្ញាធរដែលរដ្ឋបានចាត់ឲ្យគិតកំណត់ប្រយោជន៍ប្រសើរជាងគេរបស់កុមារ អាចធ្វើទៅបានដោយមិនបាច់ថ្លឹងថ្លែងប្រយោជន៍កុមារជាមួយប្រយោជន៍ដទៃឡើយ រួមទាំងប្រយោជន៍រដ្ឋ។ សម្រាប់ពត៌មានបន្ថែមចូរមើល សេចក្ដីណែនាំរបស់ UNHCR ក្នុងការកំណត់ផលប្រយោជន៍ល្អបំផុតសម្រាប់កុមារ (UNHCR Guidelines on Determining the Best Interests of the Child) អគ្គស្នងការនៃអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន ខែមិថុនា ឆ្នាំ២០០៨ ដែលមាននៅ http://www.refworld.org/

វបានសន្មតដោយសមល្មមថាមានអាយុក្រោម១៨ឆ្នាំ  ជននោះត្រូវទទួលបានជំនួយនិងការការពារសម្រាប់កុមារដែលខ្ពស់ជាងធម្មតាដោយមិនបាច់ត្រូវការបញ្ជាក់អាយុដោយលំអិតរហូតទាល់តែដល់ពេលមានការវាយតម្លៃអាយុសមស្រប។

ជនគ្រប់រូបទាំងអស់ស្ថិតនៅក្នុងយុត្តាធិការរបស់រដ្ឋមួយ រួមទាំងជនមិនមានសញ្ជាតិ មានសិទ្ធិមនុស្សស្នូល។ *ច្បាប់អន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ* ដែលមានចែងអំពីសិទ្ធិក្នុងការរួចផុតពីទាសភាព សេវកភាព និងពលកម្មដោយបង្ខិតបង្ខំ បានចែងអំពីសិទ្ធិក្នុងការទទួលដំណោះស្រាយតាមផ្លូវច្បាប់សម្រាប់ជនដែលសិទ្ធិរបស់គេក្រោមអនុសញ្ញានោះត្រូវបានគេរំលោភ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានថ្លែងថាសិទ្ធិក្នុងការទទួលដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធិភាព  ត្រូវមានបញ្ចូលកាតព្វកិច្ចឲ្យយកជនប្រព្រឹត្តល្មើសទៅតុលាការរកយុត្តិធម៌ ហើយនិងការផ្តល់សំណងសមស្របចំពោះការខូចខាតរបស់ជនរងគ្រោះ។

មានបទដ្ឋាននិងឯកសារស្តង់ដាជាច្រើនបានសង្កត់អំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារជនរងគ្រោះនិងកសិណសាក្សីដែលពុំមានសញ្ជាតិ។4  ប្រការ៥(ខ)នៃអនុសញ្ញាអន្តរជាតិស្តីអំពីការបំបាត់ការរើសអើងជាតិសាសន៍  និងប្រការ១៦(២)  នៃអនុសញ្ញាអន្តរជាតិស្តីអំពីការការពារសិទ្ធិរបស់គ្រប់អ្នកធ្វើការជាជនទេសន្តរប្រវេសន៍ហើយនិងសមាជិកក្រុមគ្រួសាររបស់គេ  មានរៀបរាប់អំពីវិស័យនេះ។ ក្នុងប្រការទាំងនេះ  ភាគីរដ្ឋត្រូវផ្តល់ការការពារប្រកបដោយប្រសិទ្ធិភាពដល់ជនគ្រប់រូបរួមទាំងអ្នកដែលមានស្ថានភាពមិនប្រក្រតីផង  ដែលទទួលរងអំពើហិង្សាផ្លូវកាយឬផ្លូវភេទ ទោះបីអំពើនោះប្រព្រឹត្តដោយមន្ត្រីរដ្ឋឬក៏ឯកជនក៏ដោយ។

អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិមួយចំនួនក៏អនុវត្តត្រូវដែរ។  *អនុសញ្ញាលេខ២៩  ស្តីអំពីពលកម្មដោយបង្ខិតបង្ខំឬដោយតម្រូវចាំបាច់(១៩៣០) និងពិធីការបន្ថែមឆ្នាំ២០១៤ (មិថុនា ២០១៤)* ធ្វើឲ្យការការពារជនរងគ្រោះពីពលកម្មដោយបង្ខិតបង្ខំនិងការជួញដូរមនុស្សមានភាពរឹងមាំ។ អនុសាសន៍លេខ២០៣ ស្តីអំពីពលកម្មដោយបង្ខិតបង្ខំ (វិធានការណ៍បន្ថែម) រៀបរាប់អំពីវិធានការណ៍ការពាររួមទាំងសម្រាប់ផ្តល់សំណងដល់ជនរងគ្រោះ *ហើយនិងអនុសញ្ញាលេខ ១៨២ ស្តីអំពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារនិយាយអំពីការការពារកុមារ។ ថែមពីលើនេះទៀត អនុសញ្ញាលេខ ១៨៩ ទាក់ទងអំពីការងារប្រកបដោយសីលធម៌សម្រាប់អ្នកធ្វើការក្នុងផ្ទះ (២០១១)* តម្រូវឲ្យរដ្ឋជាសមាជិកទាំងឡាយលើកដំកើងនិងការពារសិទ្ធិមនុស្សរបស់អ្នកធ្វើការក្នុងផ្ទះគ្រប់រូបដោយតម្រូវឲ្យមានធ្វើកិច្ចសន្យា ដោយធានាឲ្យអ្នកធ្វើការមានសិទ្ធិរក្សាអត្តសញ្ញាណប័ណ្ណនិងឯកសារធ្វើដំណើររបស់ខ្លួននិងដោយបង្កើតច្បាប់នីយ័តកម្មគ្រប់គ្រងភ្នាក់ងារផ្តល់ការងារឯកជន។

## ១.២. បញ្ហាជួបប្រទះក្នុងការការពារ

ជនរងគ្រោះពីការជួញដូរ[5]  ទោះបីឋានៈទេសន្តរប្រវេសន៍ឬឋានៈដទៃទៀតរបស់គេយ៉ាងណាក៏ដោយ  ត្រូវតែទទួលបានការការពារអំពីគ្រោះថ្នាក់បន្ថែមទៀត។  រដ្ឋមានកាតព្វកិច្ចការពារជនរងគ្រោះដើម្បីរក្សាសិទ្ធិមនុស្សរបស់គេ។  ការការពារជនរងគ្រោះ  រួមទាំងការការពារជនរងគ្រោះដែលធ្វើជាកសិណសាក្សីក្នុងការកាត់ទោសជនឧក្រិដ្ឋ  ជាផ្នែកយ៉ាងសំខាន់មួយនៃចម្លើយប្រកបដោយប្រសិទ្ធិភាពនិងពេញលេញ តបទៅនឹងការជួញដូរមនុស្សដូចដែលមាននិយមន័យចែងក្នុងប្រការ៣ នៃ ពិធីការជួញដូរមនុស្ស។[6]

ផុតពីបញ្ហាជួបប្រទះដំបូងក្នុងការសំគាល់ជនរងគ្រោះពីការជួញដូរ[7] មានបញ្ហាមួយចំនួនទៀតដែលរដ្ឋជួបប្រទះក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារ។ ជនរងគ្រោះពីការជួញដូរអាចរួញរាក្នុងការទទួលការការពារពីរដ្ឋដោយមូលហេតុដូចដែលគេរួញរាមិនចង់ឲ្យអា

4 ចូរមើល ឧទាហរណ៍ សេចក្តីថែងច្បាប់ស្តីអំពីការការពារជនរងគ្រោះនិងសាក្សីក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌សម្រាប់ជនរងគ្រោះពីឧក្រិដ្ឋកម្មនិងការប្រើអំណាចខុស (UN Declaration of Basic Principles of Justice for Victims of Crime and Abuse of Power)  A/RES/40/34 (២៩ វិច្ឆិកា ឆ្នាំ១៩៨៥) ប្រការ ៦(ឃ); សេចក្តីណែនាំស្តីអំពីភាពយុត្តិធម៌ក្នុងកិច្ចការទាក់ទងនឹងជនរងគ្រោះនិងសាក្សីជាកុមារ (Guidelines on Justice in Matters involving Child Victims and Witnesses) (លេខ៣២-៣៤); ប្រការ២៤-២៦ នៃ UNTOC; បក្រារ ៦ ដល់៨នៃពិធីការនៃការជួញដូរមនុស្ស (Trafficking in Persons Protocol); ប្រការ ១៦(២) នៃពិធីការប្រឆាំងនឹងការរត់ពន្ធទេសន្តរជនតាមដីគោក សមុទ្រ និងអាកាស (Protocol against the Smuggling of Migrants by Land, Sea, and Air) ដែលបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ (United Nations Convention against Transnational Organized Crime) (ពិធីការនៃការរត់ពន្ធទេសន្តរជន (Smuggling of Migrants Protocol)); និង ប្រការ៣២ នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនិងអំពើពុករលួយ (United Nations Convention Against Corruption) ៣១ តុលា ឆ្នាំ២០០៣ A/58/422។.

5 នៅក្នុងឯកសារនេះទាំងមូល ពាក្យ 'ការជួញដូរមនុស្ស' (human trafficking) ប្រើសម្រាប់រៀបរាប់ ការជួញដូរមនុស្ស ដូចដែលគេឲ្យនិយមន័យក្នុងប្រការ៣នៃពិធីការដើម្បីទប់ស្កាត់ សង្កត់ និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ (the Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children) ពិធីការនៃការជួញដូរមនុស្ស (Trafficking in Persons Protocol)។ ចូរមើលផងដែរ សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ (Policy Guide on Identifying Victims of Trafficking ) នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៥.

6 សម្រាប់ពត៌មានបន្ថែម ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការធ្វើឲ្យការជួញដូរមនុស្សទៅជាឧក្រិដ្ឋកម្ម (Policy Guide on Criminalizing Trafficking in Persons), នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៤

7 សម្រាប់ពត៌មានបន្ថែម ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ (Policy Guide on Identifying Victims of Trafficking) នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៥

ផ្ទាធរដ្ឋចាត់ថាគេជាជនរងគ្រោះដូច្នោះដែរ។[8] ជនរងគ្រោះអាចពុំមានទំនុកចិត្តលើស្ថាប័នរដ្ឋនិងសមត្ថភាពរបស់ស្ថាប័នទាំងនោះក្នុងការការពារជនរងគ្រោះអំពីគ្រោះថ្នាក់ ជាពិសេសក្នុងករណីសមាជិកក្រុមគ្រួសាររបស់គេស្ថិតនៅរដ្ឋឬដំបន់ក្រោមយុត្តាធិការដទៃ។ ជនរងគ្រោះខ្លះអាចចង់បន្តនៅក្រោមការគ្រប់គ្រងរបស់អ្នកជួញដូររបស់គេជាជាងទាក់ទងជាមួយអាជ្ញាធរជាតិ។ ដោយសារជនរងគ្រោះពីការជួញដូរមានអាយុ ភេទ ស្ថានភាពសេដ្ឋកិច្ច កំរិតសិក្សា និងស្ថានភាពគ្រួសារខុសៗគ្នា ហើយមានបទពិសោធន៍និងគោលបំណងខុសៗគ្នា ដំណោះស្រាយតែមួយបែបសម្រាប់គ្រប់គ្នាពុំមានប្រសិទ្ធិភាពឡើយ។[9] ជនពុំមានសញ្ជាតិដែលពុំមានសិទ្ធិបន្តស្នាក់នៅក្នុងប្រទេសដែលគេប្រទះឃើញនោះ អាចជួបឧបសគ្គក្នុងការទទួលសេវាការពារ រួមទាំងការទទួលសំណងឬការដាក់ពាក្យសុំសំណង។ ប៉ុន្តែជនទាំងអស់ទោះបីមានឋានៈទេសន្តរប្រវេសន៍របស់គេយ៉ាងណាក៏ដោយ គួរមានសិទ្ធិទទួលបាននូវសេវាអស់ទាំងនោះ។[10]

## ១.៣. ការពិចារណាអំពីការការពារ : កាតព្វកិច្ចសំខាន់ៗនិងផលប្រយោជន៍

ការការពារជាផ្នែកមួយយ៉ាងសំខាន់នៃការឆ្លើយតបពេញលក្ខណៈទៅនឹងការជួញដូរមនុស្ស។[11] លើកលែងតែជនរងគ្រោះត្រូវបានគេការពារប្រកបដោយប្រសិទ្ធិភាព ជនរងគ្រោះអាចនៅបន្តទទួលការកេងប្រវ័ញ្ចតទៅទៀត មិនអាចបានសះស្បើយពីបញ្ហាបង្កដោយការកេងប្រវ័ញ្ចជារហូត ឬក៏ធ្លាក់ទៅក្នុងកងចក្រអកុសលនៃការជួញដូរជាថ្មីទៀត។ រដ្ឋមានកាតព្វកិច្ចការពារជនរងគ្រោះ ទោះបីគេយល់ព្រមឬមិនយល់ព្រមចូលរួមក្នុងកម្មវិធីបណ្តឹងព្រហ្មទណ្ឌកេយុត្តិធម៌ក៏ដោយ។ ក្នុងករណីជនរងគ្រោះស្ម័គ្រចិត្តចូលរួមក្នុងការស៊ើបអង្កេតឬការកាត់សេចក្តី ការធ្វើជាកសិណសាក្សីរបស់គេអាចមានសារៈសំខាន់ក្រៃលែងក្នុងការបង្កើនលទ្ធភាពរដ្ឋក្នុងការរាវរក ស៊ើបអង្កេតនិងផ្តន្ទាទោសអ្នកជួញដូរ ដែលជាលទ្ធផលនឹងបង្កើនការទប់ស្កាត់ឧក្រិដ្ឋកម្មនោះហើយនិងអ្នកប្រព្រឹត្តមានភាពអោ។ ការធ្វើយ៉ាងណាឲ្យការការពារជនរងគ្រោះប្រកបទៅដោយប្រសិទ្ធិភាពនឹងបង្កើនលទ្ធភាពដែលគេអាចចូលរួមក្នុងកម្មវិធីប្តឹងអ្នកជួញដូរដើម្បីរកយុត្តិធម៌។ ដើម្បីឲ្យមានប្រសិទ្ធិភាព កម្មវិធីឆ្លើយតបរបស់រដ្ឋគួរដាក់ជនរងគ្រោះនៅកណ្តាលនិងមានភាពពេញលេញដោយមានគិត អំពីសេចក្តីត្រូវការនិងផលប្រយោជន៍របស់ជនរងគ្រោះម្នាក់ៗផង។ ចំណុចសំខាន់ៗដែលត្រូវគិតសម្រាប់ដាក់ក្នុងផែនការការពារនិងជំនួយរួមមាន :

- ជនរងគ្រោះខ្លះចង់ត្រឡប់ទៅផ្ទះជួបជុំគ្រួសារវិញ។ ខ្លះទៀតមិនអាចត្រឡប់ទៅសង្គមខ្លួនវិញបានភ្លាមទេ ហើយអាចត្រូវការទទួលការពិគ្រោះផ្តល់យោបល់ ការព្យាបាលជម្ងឺផ្លូវកាយនិងផ្លូវចិត្ត និង/ឬការរកដំណោះស្រាយផ្លូវច្បាប់ រួមទាំងតាមរយៈការចូលរួមក្នុងការស៊ើបអង្កេតនិងការកាត់សេចក្តីករណីជួញដូរ។
- ជនរងគ្រោះខ្លះមិនអាចត្រឡប់វិញរហូតដោយសារអ្នកនាំចូលឬអ្នកដទៃក្នុងប្រទេសដើមរបស់ជនរងគ្រោះអាចបន្តឲ្យមានការគំរាមមកលើជនរងគ្រោះតទៅទៀត។ ក្នុងករណីដូចនេះ ចម្លើយល្អបំផុតគឺការផ្តល់ការការពារដែលមានចីរភាពក្នុងរដ្ឋដែលគេប្រទះឃើញឬក៏ក្នុងរដ្ឋទី៣។
- សេវាការពាររបស់រដ្ឋមិនគួរបដិសេធឬមើលរំលងជនប្រភេទខ្លះ ដូចជាបុរសឬជនរងគ្រោះអំពីការជួញដូរក្នុងស្រុក។
- កម្មវិធីការពារត្រូវមានការកែសម្រួលទៅតាមសេចក្តីត្រូវការរបស់ម្នាក់ៗ ហើយយកអ្នកផ្តល់សេវាដែលមានជំនាញជាក់លាក់និងធ្លាប់មានបទពិសោធន៍ជួបបញ្ហានានាដូចដែលជនរងគ្រោះបានមាន។ អ្នកខ្លះអាចមានហានិភ័យពីការសងសឹកពីអ្នកជួញដូរ ឯខ្លះទៀតអាចមានឧបសគ្គក្នុងការទទួលការការពារដែលត្រូវការដោះស្រាយ។ ជនរងគ្រោះខ្លះអាចត្រូវការពេលយូរជាងអ្នកខ្លះក្នុងការទទួលបានសះស្បើយ ឬក៏ខ្លះត្រូវការទទួលសេវាពិសេសមួយចំនួនទើបគេអាចសះស្បើយឡើងវិញបាន។
- ការធានាឲ្យជនរងគ្រោះទទួលបានការការពារដោយប្រើជំនាញពិសេស ភាគច្រើនត្រូវការការសហការជាមួយអង្គភាពមិនមែនរដ្ឋដែលអាចជួយរដ្ឋក្នុងការបំពេញកាតព្វកិច្ចការពារជនរងគ្រោះ។
- ជនរងគ្រោះគួរមានសិទ្ធិសម្រេចកិច្ចការខ្លួនឯងនិងចូលរួមក្នុងការសម្រេចផ្សេងៗទាក់ទងនឹងវិស័យជំនួយនិងការការពាររបស់ខ្លួន។ គួរគិតអំពីសេចក្តីត្រូវការពិសេសរបស់ជនរងគ្រោះម្នាក់ៗ រួមទាំងសេចក្តីត្រូវការដែលកើត ចេញពីអាយុ ភេទ ទំនោរផ្លូវភេទ សញ្ជាតិ ជាតិសាសន៍ឬសង្គមដើម ពិការភាព ហើយនិងលក្ខណៈសម្បត្តិផ្សេងៗទៀត។

សេចក្តីត្រូវការរបស់ជនរងគ្រោះក្នុងវិស័យការពារអាចដូរចាប់តាំងពីពេលសំគាល់ដំបូង ឆ្លងកាត់ទៅដល់ការពាក់ព័ន្ធនឹងបណ្តឹងព្រហ្មទណ្ឌ ហើយនិងក្រោយពីបណ្តឹងនោះបានចប់។ ដូច្នេះហើយរដ្ឋត្រូវពិនិត្យវាយតម្លៃហានិភ័យជានិច្ចដើម្បីធានាថាសេវាការពារមានការផ្លាស់ប្តូរទៅតាមការប្រែប្រួលរបស់សេចក្តីត្រូវការ។

---

[8] សម្រាប់ពត៌មានបន្ថែម ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ (Policy Guide on Identifying Victims of Trafficking) នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៥ ផ្នែក ២.២

[9] នៅប្រទេសខ្លះ ពុំមានសេវាគ្រប់គ្រាន់សម្រាប់ជនរងគ្រោះពីការជួញដូរទេអាស្រ័យលើលក្ខណៈសម្បត្តិរបស់ជននោះ។ ឧទាហរណ៍ កន្លែងស្នាក់នៅជាពេងប្រកបដោយសុវត្ថិភាព គ្រាន់តែសម្រាប់ជនរងគ្រោះជាស្ត្រីប៉ុណ្ណោះ

[10] សម្រាប់ពត៌មានបន្ថែម ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ (Policy Guide on Identifying Victims of Trafficking) នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៥ ផ្នែក ២.២.

[11] ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ *(Policy Guide on Identifying Victims of Trafficking)* ,នីតិវិធីក្រុងបាលី *(Bali Process)* ឆ្នាំ២០១៥ ផ្នែក ២.១. ហេតុអ្វីការសំគាល់សំខាន់

ដោយសារការជួញដូរមនុស្សភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន ជាការសំខាន់បើមានការធានាឲ្យ : ក) កម្មវិធីការពារជនរងគ្រោះអនុវត្តចំពោះជនរងគ្រោះទាំងជាតិនិងទាំងមិនមែនជាតិ ហើយ ខ) មានការបង្កើតការសហការអន្តរជាតិក្នុងថ្នាក់ទ្វេភាគី តំបន់និងពហុភាគី តាមប្រការចែងក្នុងអនុសញ្ញាឧក្រិដ្ឋកម្មរៀបចំ និង ពិធីការនៃការជួញដូរមនុស្ស ដើម្បីធានាឲ្យបញ្ហានានាទាក់ទងនឹងកិច្ចការព្រំដែននិងយុត្តាធិការមិនបង្អាក់សមត្ថភាពរបស់រដ្ឋក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារជនរងគ្រោះ។ ភ្នាក់ងារកុងស៊ុលនៅប្រទេសទទួលអាចដើរតួយ៉ាងសំខាន់ក្នុងការសំគាល់ជនរងគ្រោះនិងការផ្តល់ជំនួយនិងការការពារនៅចំណុចជួបគ្នាលើកទី១ ហើយគួរមានបំពាក់អ្វីៗសមស្រប។[12]

ការប្រកាន់យកបែបបទដែលដាក់ជនរងគ្រោះនៅកណ្តាលគួរសំអាងលើគោលការណ៍ដែលគិតអំពីសុវត្ថិភាព ការរក្សាពត៌មានសម្ងាត់ និងការមិនរើសអើង ទោះបីជនរងគ្រោះចូលរួមឬមិនចូលរួមក្នុងបណ្តឹងព្រហ្មទ័ណ្ឌដើម្បីរកយុត្តិធម៌ក៏ដោយ។

**សុវត្ថិភាព:** អ្នកជួញដូរធ្វើឲ្យមានហានិភ័យខ្ពស់មិនមែនតែចំពោះជនរងគ្រោះទេ ប៉ុន្តែចំពោះក្រុមគ្រួសារគេផងដែរ។

- គួរផ្តល់សុវត្ថិភាពផ្ទាល់ខ្លួនដល់ជនរងគ្រោះ ក្រុមគ្រួសាររបស់គេហើយនិងអ្នកដទៃ

**ការរក្សាពត៌មានសម្ងាត់**

ការធ្វើឲ្យពត៌មានបាត់ភាពសម្ងាត់អាចធ្វើឲ្យសុវត្ថិភាពរបស់ជនរងគ្រោះនិងគ្រួសាររបស់គេធ្លាក់ចុះ។ ជនរងគ្រោះឧស្សាហ៍ខ្លាចមានអាមាសបង្កដោយការនិយាយរបស់សាធារណជននិងបងប្អូនខ្លួន ជាពិសេសទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទ។ ដើម្បីដោះស្រាយសេចក្តីបារម្ភនេះ :

- គួរចែករំលែកពត៌មានតែពេលណាជនរងគ្រោះផ្តល់ការឯកភាព ហើយគួរឲ្យស្ថិតក្នុងរង្វង់មនុស្សយ៉ាងតិចបំផុតដែលអាចធ្វើបាន ដើម្បីរក្សាភាពសម្ងាត់ឲ្យជនរងគ្រោះ
- ក្នុងករណីជនរងគ្រោះឯកភាពឲ្យចែករំលែកពត៌មានរបស់ខ្លួនជាមួយនឹងភ្នាក់ជំនាញដើម្បីទទួលជំនួយបន្ថែមទៀត ភ្នាក់ងារទាំងនោះនិងអ្នកដទៃ ដូចជាអ្នកកាសែតជាដើម គួរត្រូវបានប្រាប់កុំបីអាក់ខានអំពីភាពសម្ងាត់នៃពត៌មាននោះ។

**ការមិនរើសអើង**

**វិធានការណ៍ការពារជនរងគ្រោះ**ពីការជួញដូរគួរផ្តល់ទៅដល់គ្រប់ជនរងគ្រោះដោយគ្មានរើសអើង។

- ជនរងគ្រោះពីការជួញដូរត្រូវបានការពារដោយគ្មានគិតអំពីលក្ខណៈសម្បត្តិរបស់គេឡើយ[13]
- រដ្ឋមិនគ្រាន់តែមិនគួររើសអើងទេ ប៉ុន្តែគួរចាត់វិធានការណ៍ជាវិជ្ជមានប្រយុទ្ធប្រឆាំងគ្រប់រូបភាពនៃការរើសអើងដែលប្រព្រឹត្តដោយអង្គភាពឯកជននិងរដ្ឋក្នុងការការពារជនរងគ្រោះ។

## តម្រុយ : ធ្វើយ៉ាងណាឲ្យបែបបទនៃការការពារដាក់ជនរងគ្រោះឲ្យស្ថិតនៅកណ្តាល

ធ្វើយ៉ាងណាឲ្យបែបបទនៃការការពារជនរងគ្រោះពីការជួញដូរ ដាក់ជនរងគ្រោះនៅកណ្តាល ដោយមានការគិតអំពីសុវត្ថិភាពរបស់ជនរងគ្រោះនិងក្រុមគ្រួសាររបស់គេ ហើយនិងការរក្សាពត៌មានរបស់គេឲ្យនៅសម្ងាត់។ កម្មវិធីការពារជនរងគ្រោះគួរអនុវត្តជំពោះ ជនរងគ្រោះពីការជួញដូរគ្រប់រូបដោយមិនរើសអើង ហើយគួរមានភាពទន់ភ្លន់ដែលអាចបត់បែនទៅតាមសេចក្តីត្រូវការរបស់ជនរងគ្រោះម្នាក់ៗរួមទាំងតាមរយៈការសហការប្រកបដោយប្រសិទ្ធិភាពជាមួយអង្គការក្រៅរដ្ឋាភិបាលជំនាញ។

[12] ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរមនុស្ស Guidelines for the Identification of Victims of Trafficking in Human Beings: Especially for Consular Services and Border Guards ជាពិសេសសម្រាប់សេវាកុងស៊ុលនិងអ្នកយាមព្រំដែន សភាពអឺរ៉ុប ឆ្នាំ២០១៣

[13] សម្រាប់ពត៌មានបន្ថែម ចូរមើលផ្នែក ១.២.

# ផ្នែកទី២:

## ការអនុវត្តការការពារ

ជនរងគ្រោះពីការជួញដូរអាចត្រូវការការការការពារក្នុងបរិបទសំខាន់ៗបី ៖
១ ការការពារដំបូង
២ ក្នុងកំឡុងពេលដំណើរការបណ្តឹងព្រហ្មទណ្ឌក្នុងការកេយុត្តិធម៌
៣ ដំណាក់កាលដែលយកចីរភាពជាមូលដ្ឋាន រួមទាំងដើម្បីជួយឲ្យគេរួមរស់ក្នុងសង្គមឡើងវិញបាន[14]
សេចក្តីត្រូវការរបស់ជនរងគ្រោះម្នាក់ៗដូរក្នុងដំណាក់កាលទាំងអស់នេះ ដូច្នេះហើយជាការសំខាន់ណាស់ដែលរដ្ឋពិនិត្យវាយតម្លៃនៅគ្រប់ដំណាក់កាលដើម្បីឲ្យដឹងច្បាស់ថាសេវាការពារត្រូវបានផ្តល់សមស្របទៅតាមសេចក្តីត្រូវការឬទេ។

## ២.១. ការការពារដំបូង

ប្រភេទនៃការការពារផ្តល់ឲ្យនៅពេលជនរងគ្រោះសន្មតត្រូវបានសំគាល់ មានសារៈសំខាន់ណាស់ចំពោះជោគវាសនានៃផែនការការពារអនុវត្តដោយអ្នកផ្គត់ផ្គង់សេវា។ ជាពិសេសវិធានការណ៍ការពារដែលប្រើក្នុងដំណាក់កាលនេះមានសារៈសំខាន់ណាស់ក្នុងការបង្កឲ្យមានទំនាក់ទំនងប្រកបដោយទុកចិត្តនិងសហការរវាងជនរងគ្រោះនិងអ្នកផ្គត់ផ្គង់សេវា ។ ការផ្តល់ការការពារដែលធ្វើឲ្យមានសុវត្ថិភាពនិងមានចំនួនគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់ជនរងគ្រោះមិនត្រូវផ្សារភ្ជាប់ទៅនឹងការស្ម័គ្រចិត្តរបស់គេក្នុងការសហការជាមួយអាជ្ញាធរឡើយ។

វត្ថុបំណងចំបងនៅពេលនេះគឺដើម្បីដឹងនិងដោះស្រាយសេចក្តីត្រូវការដែលបន្ទាន់ ហើយនិងការបារម្ភរបស់ជនរងគ្រោះពីការជួញដូរ។ សេចក្តីត្រូវការទាំងនោះរួមមាន ៖

- ឯកជនភាព សុវត្ថិភាព និងសន្តិសុខសម្រាប់ជនរងគ្រោះ គ្រួសារ និងមិត្តភ័ក្តជិតដិត
- លទ្ធភាពក្នុងការទទួលយកបានរបស់របរត្រូវការជាមូលដ្ឋានដូចជាអាហារ សម្លៀកបំពាក់ហើយនិងទីស្នាក់នៅប្រកបដោយសុវត្ថិភាព
- ទំនាក់ទំនងជាមួយក្រុមគ្រួសារនិងការស្រាវជ្រាវរកក្រុមគ្រួសារប្រសិនបើគ្មានការសង្ស័យថាគេទាំងនោះគ្មានការពាក់ព័ន្ធនឹងការជួញដូរមនុស្សទេហើយនិងបើការទំនាក់ទំនងនោះមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះឬក្រុមគ្រួសារទេ។
- សេវាមើលជម្ងឺបន្ទាន់
- យោបល់អំពីច្បាប់និងទេសន្តរប្រវេសន៍

នាពេលនេះ ជាការប្រសើបំផុតបើជនរងគ្រោះត្រូវបានផ្តល់ពត៌មានលំអិតអំពីសិទ្ធិរបស់គេ ក៏ដូចជាឲ្យដឹងអំពីវិសាលភាព ប្រភេទ និងមុខងារនៃកម្មវិធីជំនួយនិងការការពារ ហើយនិងកាតព្វកិច្ចនិងការទទួលខុសត្រូវរបស់ជនរងគ្រោះ ពាក់ព័ន្ធនឹងកិច្ចការទាំងនោះ។ គួរផ្តល់ពត៌មាននៅពេលដែលជនរងគ្រោះអាចមើលឃើញនិងយល់ពត៌មានដែលត្រូវផ្តល់ទាំងអស់នោះ។ អាចត្រូវមានអ្នកបកប្រែភាសាប្រសិនបើជនរងគ្រោះមិនចេះភាសាដែលគេនិយាយនៅកន្លែងនោះ។ ការប្រាប់ឲ្យជនរងគ្រោះដឹងអំពីការមានជំនួយ អាចបន្ធូរអារម្មណ៍ភ័យព្រួយរបស់ជនរងគ្រោះ ហើយអាចជួយឲ្យគេសម្រេចអំពីជំហាននិងកម្មវិធីខាងមុខបាន។ ដំណាក់ការដំបូងនៃការមើលថែនេះមានសារៈសំខាន់ណាស់ក្នុងការរៀបចំផែនការប្រកបដោយចីរភាព ហើយនិងវាផ្តល់កម្លាំងឲ្យជនរងគ្រោះអាចសម្រេចអំពីប្រភេទនៃសេវាការពារដែលគេចង់បាន ហើយនិងថាតើគេចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មឬទេ។

> **តម្រុយ: ការពារជនរងគ្រោះទោះបីគេធ្វើឬមិនធ្វើការសហការក៏ដោយ**
> រដ្ឋគួរធ្វើតាមកាតព្វកិច្ចរបស់ខ្លួនដើម្បីការពារជនរងគ្រោះដោយមិនគិតអំពីឋានៈទេសន្តរប្រវេសន៍ឬឋានៈអ្វីផ្សេងទៀតរបស់គេ ហើយនិងតើគេស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មក៏ដោយ។

[14] សម្រាប់ពត៌មានអំពីការសំគាល់ជនរងគ្រោះពីការជួញដូរនៅចំណុចជួបគ្នាដំបូងនិងទូទាំងសេចក្តីសំភាស(រួមទាំងសេចក្តីសំភាសសម្រាប់វត្ថុបំណងនៃការរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម) ចូរមើលចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ (Policy Guide on Identifying Victims of Trafficking),នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៥

ជនរងគ្រោះដែលសន្មតថាជាកុមារគួរបញ្ជូនភ្លាមទៅអាជ្ញាធរការពារកុមារដើម្បីធ្វើការវាយតម្លៃអំពីអាយុ តែងតាំងអ្នកអាណាព្យាបាល ហើយនិងធ្វើការសម្រេចដែលប្រសើរបំផុតដើម្បីបង្កើតកម្មវិធីមើលថែបណ្តោះអាសន្នសមស្រប។ បើកុមារមានមនុស្សចាស់អមជាមួយ ត្រូវធ្វើការសម្រេចថាតើអ្នកអាណាព្យាបាលនោះអាចជំណាងកុមារនោះនិងគិតអំពីផលប្រយោជន៍ខ្ពស់បំផុតសម្រាប់កុមារនោះឬទេ ឧទាហរណ៍មានការសង្ស័យថាអ្នកអាណាព្យាបាលនោះមានការពាក់ព័ន្ធនឹងការជួញដូរឬការកេងប្រវ័ញ្ច។[15] ការទទួលខុសត្រូវរបស់អ្នកអាណាព្យាបាលមានរួមទាំងការធ្វើឲ្យកុមារមានការមើលថែ កន្លែងស្នាក់នៅ ការមើលសុខភាព ការគាំទ្រផ្លូវចិត្តនិងសង្គម ការសិក្សានិងការរៀនភាសា ហើយនិងឲ្យគេដឹងជានិច្ចអំពីសិទ្ធិរបស់គេ ព្រមទាំងជួយរកសេវាការពារដែលមានចីរភាពដែលផ្តល់ផលប្រសើរបំផុតសម្រាប់កុមារនោះ។[16]

> ⚠ *ប្រយ័ត្ន :*
>
> *មានហានិភ័យដោយអ្នកជួញដូរអាចបង្កប់ខ្លួនចូលក្នុងកម្មវិធីជំនួយ ឬរាវរកព័ត៌មានអំពីទីកន្លែងរបស់ជនរងគ្រោះ។ អ្នកផ្តល់សេវានានាគួរចាប់អារម្មណ៍អំពីហានិភ័យនេះហើយមិនត្រូវឲ្យជនណាដែលខ្លួនមិនស្គាល់អត្តសញ្ញាណហើយនិងតំណែង។ល។ដឹងនូវព័ត៌មានរបស់ជនរងគ្រោះឡើយ។*

ជនទាំងឡាយណាដែលជួបដំបូងគេជាមួយជនដែលអាចរងគ្រោះត្រូវចាត់វិធានការណ៍ការពារសន្តិសុខដល់ជនរងគ្រោះនោះ ហើយបុគ្គលិកដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះក៏ត្រូវធ្វើដូច្នោះដែរ។ យោងតាមការវាយតម្លៃទំហំហានីភ័យ គេអាចចាត់វិធានការណ៍សមស្របដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ។ វិធានការណ៍សន្តិសុខអាចមានតាំងពីការដាក់ឲ្យមានវត្តមានបុគ្គលឹកសន្តិសុខឬការទាក់ទងផ្ទាល់និងការសហការជាមួយប៉ូលិស រហូតទៅដល់ការដាក់វត្តមានក្រុមហ៊ុនសន្តិសុខឯកជនប្រចាំនៅក្នុងរោងជម្រក។

ក្នុងករណីជនរងគ្រោះស្នាក់នៅកន្លែងដែលមិនមែនជារោងជម្រក គេត្រូវគិតអំពីបញ្ហាសន្តិសុខដែលជនរងគ្រោះ គ្រួសារ មិត្តភ័ក្ត និងអ្នកផ្តល់សេវាទាំងឡាយអាចរងទទួល រួមទាំងលទ្ធភាពក្នុងការប្រើបណ្តាញទាក់ទង និងកំរិតស្ទាត់ជំនាញរបស់ប៉ូលិសប្រចាំដំបន់នោះ។ វាជាការសំខាន់ណាស់ដែលគ្រប់បុគ្គលឹកទាំងអស់ពាក់ព័ន្ធនឹងការផ្តល់ជំនួយ ដល់ជនរងគ្នីស្នាក់នៅប្រកបដោយសុវត្ថិភាពរបស់ជនរងគ្រោះអាចមានប្រភេទជារោងឬប្រភេទផ្សេងទៀតដែលសមស្របតាមតម្រូវការរបស់គេ ហើយគួរមានសេរីភាពក្នុងការដើរហើរ។ គេមិនគួរជាប់នៅក្នុងកន្លែងឃុំឃាំង ដូចជាមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ពន្ធនាគារ ឬបន្ទប់បិទជិតដទៃទៀតដែលគេមិនអាចចេញចូលដោយសេរីបាននោះទេ។ 18 ជនរងគ្រោះអាចត្រូវការសេវាពេទ្យភ្លាមសេវាសុខាភិបាលឯទៀត ក៏ដូចជាជំនួយខាងវិស័យច្បាប់និងអន្តោប្រវេសន៍។

ទីស្នាក់នៅប្រកបដោយសុវត្ថិភាពរបស់ជនរងគ្រោះអាចមានប្រភេទជារោងឬប្រភេទផ្សេងទៀតដែលសមស្របតាមតម្រូវការរបស់គេ ហើយគួរមានសេរីភាពក្នុងការដើរហើរ។ គេមិនគួរជាប់នៅក្នុងកន្លែងឃុំឃាំង ដូចជាមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ពន្ធនាគារ ឬបន្ទប់បិទជិតដទៃទៀតដែលគេមិនអាចចេញចូលដោយសេរីបាននោះទេ។ 18 ជនរងគ្រោះអាចត្រូវការសេវាពេទ្យភ្លាមសេវាសុខាភិបាលឯទៀត ក៏ដូចជាជំនួយខាងវិស័យច្បាប់និងអន្តោប្រវេសន៍។

## តម្រុយ: ចូរផ្តល់ឱកាសពិចារណាដល់ជនរងគ្រោះពីការជួញដូរ

ចូរផ្តល់ឱកាសពិចារណាដល់ជនរងគ្រោះពីការជួញដូរដើម្បីឲ្យគេអាចចាប់ផ្តើមសះស្បើយឡើងវិញ។ ឱកាសពិចារណានិងការគាំទ្រនានាដែលពាក់ព័ន្ធរួមទាំងទិដ្ឋាការបណ្តោះ អាសន្នសម្រាប់ជនរងគ្រោះពីការជួញដូរឆ្លងដែន គួរផ្តល់ទៅឲ្យជនរងគ្រោះទោះបីគេស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តចូលរួមក្នុងបណ្តឹងប្រឆាំងនឹងអ្នកជួញដូរក៏ដោយ។

បទពិសោធន៍កន្លងមកបញ្ជាក់ថា ដោយសារឧក្រិដ្ឋកម្មប្រភេទនេះធ្វើឲ្យជនរងគ្រោះស្លុតរន្ធត់ គេគួរផ្តល់"ឱកាសពិចារណា"គឺទុកឲ្យជនរងគ្រោះមានពេលដើម្បីបានធូរ

---

[15] គេត្រូវពិគ្រោះជាមួយកុមារដើម្បីឲ្យដឹងអ្វីទៅដែលមានប្រយោជន៍ជាងគេសម្រាប់រូបគេ។ ប្រការ ១២ នៃ Convention on the Rights of the Child (CRC) កំណត់ថាគេគួរឲ្យទម្ងន់ដល់ទស្សនៈរបស់កុមារទៅតាមអាយុនិងភាពចាស់ទុំរបស់កុមារនោះ។ ក្នុងការពិគ្រោះជាមួយកុមារ គេគួរពិចារណាអំពីប្រការ ១៦នៃ CRC គឺការពារកុមារពីការជ្រៀតជ្រែកតាមតែចិត្តចង់ធ្វើឬដោយខុសច្បាប់ទៅក្នុងកិច្ចការសម្ងាត់ គ្រួសារ ឬលិខិតទាក់ទង ហើយនិងប្រការ ១៧ ដែលទាក់ទងនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការធានាឲ្យកុមារមានសិទ្ធិទទួលព័ត៌មាន។

[16] ចូរមើលសេចក្តីណែនាំស្តីអំពីការការពារជនរងគ្រោះពីការជួញដូរជាកុមារ (Guidelines on the Protection of Child Victims of Trafficking) កំណត់ចំណាំបច្ចេកទេសរបស់ UNICEF, UNICEF ឆ្នាំ ២០០៦ ទំព័រ ១៦- ១៧.

[17] ចូរមើលកូនសៀវភៅស្តីអំពីជំនួយផ្ទាល់ដល់ជនរងគ្រោះជាកុមារ (The IOM Handbook on Direct Assistance to Victims of Trafficking) IOM ឆ្នាំ២០០៥ ផ្នែក ៤.២.៦

[18] ចូរមើលផងដែរ គោលការណ៍ដែលគួរមាននិងសេចក្តីណែនាំស្តីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស (Recommended Principles and Guidelines on Human Rights and Human Trafficking) (E/2002/68/Add.1) អគ្គស្នងការនៃអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន សេចក្តីណែនាំទី ៦(១)

ធូរស្រាលនិងជាឡើងវិញ ហើយសម្រេចថានឹងជួយឬអត់ក្នុងកម្មវិធីស៊ើបអង្កេតនិងផ្តន្ទាទោសជនឧក្រិដ្ឋ។ ឱកាសពិចារណាមានអំឡុងខុសៗគ្នាពីរដ្ឋមួយទៅរដ្ឋមួយ តែជាធម្មតាចន្លោះពី៣០ទៅ៩០ថ្ងៃ។[19] បញ្ហា បន្ថែមទៀតដែលមានគឺជនរងគ្រោះពីការជួញដូរមិនមែនជនដែលមានសញ្ជាតិ គឺមានឋានៈអន្តោប្រវេសន៍មិនប្រក្រតី។ ផែនការការពារជនបរទេសអាចតម្រូវឲ្យមានការផ្តល់ទិដ្ឋការបណ្តោះអាសន្ន ដើម្បីអនុញ្ញាតិឲ្យជនរងគ្រោះស្នាក់នៅក្នុងប្រទេសក្នុងអំឡុងពេលនៃឱកាសពិចារណា។

បើជនរងគ្រោះទទួលបានការឧបត្ថមនិងពេលគ្រប់គ្រាន់សម្រាប់ការសះស្បើយឡើងវិញនិងសម្រាប់គិតអំពីអនាគតរបស់គេ គេអាចមានចិត្តស្ម័គ្រចិត្តនិងមានសមត្ថភាពចជាងក្នុងការគាំទ្រកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម។ មានរដ្ឋជាច្រើនផ្តល់សិទ្ធិរស់នៅជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ដូចជានៅពេលដែលជនរងគ្រោះបានជួយក្នុងកម្មវិធីស៊ើបអង្កេតនិងផ្តន្ទាទោសអ្នកជួញដូរ ហើយជនរងគ្រោះនឹងស្ថិតក្នុងភាពគ្រោះថ្នាក់ប្រសិនបើគេវិលត្រឡប់ទៅប្រទេសដើមវិញ។

### តម្រុយ: ការពារជនរងគ្រោះពីការជួញដូរមនុស្សតាមបែបបទដែលប្រសើរបំផុត

សេចក្តីណែនាំទី ៦ របស់ការិយាល័យស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស អនុសាសន៍អំពីគោលការណ៍និងសេចក្តីណែនាំស្តីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស ផ្តល់ដំបូន្មានថារដ្ឋ និងបើត្រូវ អង្គការអន្តរដ្ឋាភិបាលនិងក្រៅរដ្ឋាភិបាលផងដែរ គួរពិចារណា ៖

- ធ្វើយ៉ាងណាកុំដាក់ជនរងគ្រោះក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ឬប្រភេទដទៃ
- ធ្វើយ៉ាងណាកុំបង្ខំជនរងគ្រោះឲ្យទទួលសេវាការពារឬជំនួយដែលគេមិនឯកភាពទទួល
- ផ្តល់ពត៌មានទៅជនរងគ្រោះអំពីសិទ្ធិរបស់គេក្នុងការទាក់ទងជាមួយតំណាងស្ថានទូតឬកុងស៊ុលរបស់រដ្ឋនៃសញ្ជាតិរបស់គេ។
- ការពារជនរងគ្រោះអំពីការគំរាម បង្កគ្រោះថ្នាក់ ឬការសងសឹកពីអ្នកជួញដូរ រួមទាំងដោយរក្សាពត៌មានសម្ងាត់និងអត្តសញ្ញាណរបស់គេ។

## ២.២. ការការពារតាមរយៈកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម

មិនត្រូវបង្ខំជនរងគ្រោះឲ្យចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មឡើយ ប៉ុន្តែផ្តល់អំណាចឲ្យគេជ្រើសរើសថាតើគេចង់ចូលរួមឬអត់។ ចំពោះជនរងគ្រោះទាំងឡាយណាដែលស្ម័គ្រចិត្តធ្វើការសហការក្នុងការស៊ើបអង្កេតនិងរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម គេត្រូវទទួលបានការការពារពិសេស។ ការកាត់សេចក្តីឧក្រិដ្ឋកម្មជួញដូរមនុស្សនិងឧក្រិដ្ឋកម្មពាក់ព័ន្ធទាំងឡាយ ឧស្សាហ៍ពឹងផ្អែកលើកសិណសាក្សីក្នុងករណីពុំមានវត្ថុតាងច្បាស់ មានន័យថាភាគច្រើនពុំបានជោគជ័យទេប្រសិនបើគ្មានការចូលរួមពីជនរងគ្រោះ។ បើជនរងគ្រោះមិនអាចផ្តល់ភស្តុតាងដែលគួរឲ្យទុកចិត្ត ឬក៏បើមានការរារែកក្នុងការផ្តល់ភស្តុតាង វាអាចធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់បណ្តឹងឬលទ្ធផលរបស់វា ដែលធ្វើឲ្យសេចក្តីសង្ឃឹមរបស់រដ្ឋថាឧក្រិដ្ឋជននឹងត្រូវបានកាត់ទោសនោះទៅជាពុំបានសម្រេច។

ប្រសិនបើជនរងគ្រោះមិនបានទទួលការគាំទ្រពីរដ្ឋក្នុងបណ្តឹងរកយុត្តិធម៌ដើម្បីឲ្យគេអស់ចិត្តទេ វាអាចធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរដ្ឋក្នុងការជួយជនរងគ្រោះទទួលបានការសះស្បើយឡើងវិញ។[20] ការធ្វើយ៉ាងណាឲ្យជនរងគ្រោះទទួលបានការគាំទ្រនិងការការពារសមស្របនៅគ្រប់ដំណាក់ការនៃកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម មិនគ្រាន់តែសំខាន់សម្រាប់ការពារសិទ្ធិរបស់គេជាជនរងគ្រោះពីឧក្រិដ្ឋកម្មប៉ុណ្ណោះទេ ប៉ុន្តែវាក៏ចាំបាច់សម្រាប់ការចូលរួមប្រកបដោយសុវត្ថិភាព ប្រសិទ្ធិភាព និងមានតម្លៃក្នុងការកាត់ទោសអ្នកជួញដូរ។

[19] ចូរមើលឧទាហរណ៍ Cathy Zimmerman et al., Stolen Smiles: ផលវិបាកសុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់ស្ត្រីនិងក្មេងជំទង់ដែលគេបានជួញដូរចូលទៅក្នុងអឺរ៉ុប (The physical and psychological health consequences of women and adolescents trafficked into Europe) មហាវិទ្យាល័យអនាម័យនិងវេជ្ជសាស្ត្រដំបន់ក្តៅ ក្រុងឡុង ឆ្នាំ២០០៦ ទំព័រ ៣

[20] ចូរមើលផ្នែក ១.១. ខាងលើស្តីអំពី កាតព្វកិច្ចរដ្ឋក្នុងការការពារជនរងគ្រោះ ហើយនិងផ្នែលក ២.១. អំពីផលប្រយោជន៍របស់គេក្នុងការធ្វើដូច្នេះ

## តម្រុយៈ ធ្វើការវាយតម្លៃហានិភ័យនៅគ្រប់ដំណាក់ការនៃកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម

សេចក្ដីត្រូវការរបស់ជនរងគ្រោះក្នុងវិស័យការពារមានភាពខុសគ្នានៅពេលមុន ក្នុង និងក្រោយកម្មវិធីកាត់ទោស។ ដូច្នេះហើយ វិធីប្រសើរបំផុតគឺរដ្ឋធ្វើការវាយតម្លៃហានិភ័យនៅដំណាក់និមួយៗនៃកម្មវិធីនោះដើម្បីធានាឲ្យសេវាការពារផ្ដល់ដល់ជនរងគ្រោះមានការផ្លាស់ប្ដូរត្រូវទៅតាមសេចក្ដីត្រូវការដែលប្រែប្រួល។

### ការការពារមុនការកាត់ទោស

ជាផ្នែកមួយនៃការទទួលសំណងប្រកបដោយប្រសិទ្ធិភាពសម្រាប់ខ្លួន ជនរងគ្រោះអាចចង់រកយុត្តិធម៌ដោយចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម។ ក្នុងករណីភាគច្រើន គេធ្វើជាអ្នកដើមបណ្ដឹងនិងជាកសិណសាក្សីដែលមានន័យថាគេត្រូវមានវត្តមានក្នុងពេលស៊ើបអង្កេតហើយនិងក្នុងករណីខ្លះ ពេលសវនាការក្នុងតុលាការ។

មានផ្នែកសំខាន់មួយក្នុងវិស័យការពារមុននឹងការកាត់ទោសចាប់ផ្ដើម គឺក្នុងពេលធ្វើការស៊ើបអង្កេតនិងពេលរៀបចំសំណុំរឿង។ ជនរងគ្រោះត្រូវទទួលពត៌មានជារៀងរហូត ឧទាហរណ៍ដូចជាការឲ្យដឹងថាអ្វីកំពុងកើតឡើង តើវិធីទាំងឡាយនោះប្រហែលនឹងស៊ីពេលប៉ុន្មាន ហេតុអ្វីបានជាគេយករបស់របរផ្ទាល់ខ្លួនរបស់គាត់ទៅធ្វើជាវត្ថុតាង ហើយនិងពេលណាគេនឹងរបស់របរទាំងនោះមកប្រគល់ឲ្យវិញ។ ក្នុងដំណាក់កាលមុនការកាត់ទោស ជនរងគ្រោះអាចត្រូវរៀបចំខ្លួនសម្រាប់ដំណាក់ការកាត់ទោស ដែលពេលនោះអាចត្រូវផ្ដល់ភស្តុតាងជាកសិណសាក្សី។ ការរៀបចំគឺមានទទួលការពិគ្រោះនិងផ្ដល់យោបល់និងការគាំទ្រផ្លូវចិត្ត។ ការគាំទ្រនេះគួរមានបន្តរហូតដល់ដំណាក់កាលកាត់សេចក្ដី។

នៅក្នុងរដ្ឋខ្លះ ច្បាប់តម្រូវឲ្យមានការគាំទ្រជនរងគ្រោះ-សាក្សីមុនពេលកាត់សេចក្ដី។ ការគាំទ្រទាំងនោះអាចរួមមានការប្រើអ្នកជំនាញមានសញ្ញាប័ត្រដើម្បីត្រៀមជនរងគ្រោះសម្រាប់ពេលកាត់សេចក្ដី ដូចជាដើរអមនៅពេលដើរចូលបន្ទប់តុលាការ ពន្យល់នីតិវិធីរបស់តុលាការហើយនិងជួយឲ្យគេយល់សំនួរនានាដែលគេទទួល។

បើសមស្របហើយមិនប្រឆាំងនឹងសិទ្ធិរបស់ភាគីចុងចោទ ការដាក់ជនជាប់ចោទថាជាអ្នកជួញដូរឲ្យនៅក្នុងឃុំមុនពេលកាត់សេក្ដី អាចជួយការពារមិនឲ្យជនរងគ្រោះនិងក្រុមគ្រួសាររបស់គេរងការសងសឹកពីជនជាប់ចោទ។ ការដាក់ឃុំមុនពេលកាត់សេចក្ដីដូចនេះអាចធ្វើឲ្យជនរងគ្រោះនិងក្រុមគ្រួសាររបស់គេមានអារម្មណ៍កាន់តែកក់ក្ដៅអំពីសន្តិសុខរបស់ខ្លួន ហើយបង្កើនឱកាសថានឹងមានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ដោយការទប់ស្កាត់មិនឲ្យជនសង្ស័យថាជាអ្នកជួញដូរ ធ្វើអ្វីប៉ះពាល់ដល់ភស្តុតាង ឬក៏មានឥទ្ធិពលដល់ជនរងគ្រោះឬសាក្សីឯទៀតៗ។[21]

> **តម្រុយ** : ផ្ដល់ការគាំទ្រដល់ជនរងគ្រោះនិងសាក្សីនៃការជួញដូរមនុស្សមុនពេលកាត់ក្ដីជនល្មើស
>
> ប្រការស្ដីអំពីការការពារចែងក្នុងពិធីការនៃការជួញដូរមនុស្ស មានចែងអំពីស្តង់ដាអប្បបរមានៃការគាំទ្រដល់ជនរងគ្រោះនិងសាក្សីនៃការជួញដូរមនុស្សមុនពេលកាត់ក្ដីជនល្មើស។ រដ្ឋនានាគួរដាក់អនុវត្តនីតិវិធីផ្លូវការមួយសម្រាប់ផ្ដល់ជំនួយទាំងនោះ។ អង្គការក្រៅរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលដែលស្ទាត់ជំនាញនិងយល់អំពីរបៀបរបបប្រើក្នុងការកាត់សេចក្ដីក្នុងរឿងឧក្រិដ្ឋកម្ម ហើយធ្លាប់មានការហាត់រៀនជំនាញក្នុងការផ្ដល់ជំនួយដល់ជនរងគ្រោះ អាចជួយក្នុងការផ្ដល់សេវាជំនួយទាំងនោះ។

ការសម្រេចថាតើគួរឬមិនគួរបញ្ជូនជនរងគ្រោះពីការជួញដូរឆ្លងដែនទៅប្រទេសដើមរបស់គេវិញក្នុងចន្លោះពេលនៃការស៊ើបអង្កេតដំបូងនិងពេលកាត់សេចក្ដី ត្រូវធ្វើឡើងដោយគិត បញ្ចូលអំពីផលប្រយោជន៍ប្រសើរបំផុតរបស់ជនរងគ្រោះផង។ការសម្រេចបែបបណានោះអាចអាស្រ័យលើយន្តការនៃការការពារដែលគេប្រើក្នុងប្រទេសដើមនោះ ការលំបាកក្នុងការដឹកជនរងគ្រោះត្រឡប់មកប្រទេសដែលធ្វើការកាត់សេចក្ដីវិញនៅពេលជិតដល់ដំណាក់កាលកាត់សេចក្ដីឬលទ្ធភាពក្នុងការធ្វើកសិណសាក្សីពីចម្ងាយ(តាមបណ្ដាញអ៊ិនធឺណិតឬបច្ចកវិទ្យាផ្សេងដែលអាចការពារពត៌មានសម្ងាត់របស់សាក្សី)។ ក្នុងករណីធ្វើជាកសិណសាក្សីក្នុងតុលាការមិនបានឬមិនសមស្រប អាចឲ្យសាក្សីធ្វើសេចក្ដីថ្លែងជាលាយលក្ខណ៍អក្សរបាន។ [22]

[21] សៀវភៅហ្វឹកហាត់អំពីការទប់ទល់នឹងការជួញដូរមនុស្សសម្រាប់អ្នកអនុវត្តក្នុងការរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម (Anti-Human Trafficking Training Manual for Criminal Justice Practitioners) ភាគ១១: សេចក្ដីត្រូវការរបស់ជនរងគ្រោះក្នុងដំណើរការតុលាការក្នុងបណ្ដឹងអំពីការជួញដូរមនុស្ស (Victims' needs in criminal justice proceedings in trafficking in persons cases) UNODC/UN.GIFT, ឆ្នាំ២០០៩ ទំព័រ ៨.

[22] សៀវភៅហ្វឹកហាត់អំពីការទប់ទល់នឹងការជួញដូរមនុស្សសម្រាប់អ្នកអនុវត្តក្នុងការរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម (Anti-Human Trafficking Training Manual for Criminal Justice Practitioners) ភាគ១១: សេចក្ដីត្រូវការរបស់ជនរងគ្រោះក្នុងដំណើរការតុលាការក្នុងបណ្ដឹងអំពីការជួញដូរមនុស្ស (Victims' needs in criminal justice proceedings in trafficking in persons cases) UNODC/UN.GIFT, ឆ្នាំ២០០៩ ទំព័រ ៧-៨.

## ការការពារក្នុងដំណាក់កាលកាត់សេចក្តី

សម្រាប់ជនរងគ្រោះពីការជួញដូរភាគច្រើន ការឈរមុខតុលាការជាបទពិសោធន៍ប្រកបដោយការលំបាក។ ផ្នែកនានាក្នុងពិធីកាត់សេចក្តីដែលធ្វើឲ្យការភិតភ័យកាន់តែធ្ងន់ធ្ងរឡើង ដូចជាការផ្តល់ចម្លើយកសិណសាក្សី គួរធ្វើឲ្យខ្លីបំផុតដែលអាចធ្វើបាន។

ដើម្បីជួយជនរងគ្រោះពីការជួញដូរក្នុងការផ្តល់ភស្តុតាងក្នុងតុលាការ រដ្ឋខ្លះបានបង្កើតឲ្យមាន "វិធានការណ៍ជួយសាក្សីដែលងាយរងគ្រោះ" ហើយនិង "ឧបករណ៍ជំនួយសាក្សី" ។ វិធានការណ៍ទាំងនេះគឺដើម្បីជួយឲ្យជនរងគ្រោះមានលទ្ធភាពធ្វើជាកសិណសាក្សីបានល្អបំផុត ដោយធ្វើឲ្យនៅទាបបំផុតហានិភ័យពីការបំភិតបំភ័យស្លុតរន្ធត់ថែមទៀត ការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន និង/ឬការធ្វើឲ្យមានអាមាសនៅមុខសាធារណជនខ្លាំងពេក។ ទោះបីតម្លាភាពជាកត្តាចំបងនៃពិធីច្បាប់ វាត្រូវមានតុល្យភាពជាមួយសិទ្ធិរបស់អ្នកចូលរួមក្នុងបណ្តឹងឧក្រិដ្ឋកម្មក្នុងការទទួលបានសុវត្ថិភាពនិងការការពារពីការភិតភ័យឬភាពអាមាសនៅមុខជាសាធារណជនខ្លាំងពេក។ រដ្ឋគួរចងចាំថាវិធានការណ៍ការពារជនរងគ្រោះក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មត្រូវមានភាពសមរម្យ ចាំបាច់ ហើយនិងសមនឹងទម្ងន់រឿង ជាពិសេសដោយសារវាអាចជះឥទ្ធិពលដល់សិទ្ធិរបស់ភាគីចុងចោទក្នុងការទទួលបានយុត្តិធម៌ ជនរងគ្រោះក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មត្រូវមានភាពសមរម្យ ចាំបាច់ ហើយនិងសមនឹងទម្ងន់រឿង ជាពិសេសដោយសារវាអាចជះឥទ្ធិពលដល់សិទ្ធិរបស់ភាគីចុងចោទក្នុងការទទួលបានយុត្តិធម៌ក្នុងការមានឱកាសឆ្លើយបំភ្លឺក្នុងសវនាការ។ វិធានការណ៍និងឧបករណ៍ជំនួយសាក្សីទាំងឡាយសម្រាប់ការពារជនរងគ្រោះនិងសាក្សីនៃការជួញដូរក្នុងអំឡុងពេលនៃពិធីកាត់សេចក្តីអាចរួមមាន ៖

- អនុញ្ញាតិឲ្យជនរងគ្រោះបង្ហាញភស្តុតាងតាមរយៈបណ្តាញវីដេអូ (Video link) ឬទូរទស្សន៍ឯកជនពិសេស(CCTV)
- កំណត់ឲ្យនៅទាបទំនាក់ទំនងរវាងជនរងគ្រោះនិងជនជាប់ចោទនិងសាធារណជន ដោយរួមទាំងវិធីប្រើបាំងឬបិទទ្វារបន្ទប់តុលាការ
- អនុញ្ញាតិឲ្យអ្នកជំនួយម្នាក់នៅជាមួយពេលជនរងគ្រោះធ្វើការផ្តល់ភស្តុតាង
- បង្កើតច្បាប់អនុញ្ញាតិឲ្យភស្តុតាងដែលជនរងគ្រោះបានផ្តល់ក្នុងពិធីកាត់សេចក្តីចាស់ យកមកប្រើដដែលទៀតក្នុងពិធីកាត់សេចក្តីលើកក្រោយៗដើម្បីកាត់បន្ថយការបង្កឲ្យមានភាពស្លុតរន្ធត់ឡើងវិញ។
- អនុញ្ញាតិឲ្យជនរងគ្រោះដែលស្ថិតនៅបរទេសផ្តល់ភស្តុតាងតាមរយៈបណ្តាញវីដេអូប្រសិនបើការធ្វើដំណើរទៅតុលាការក្នុងប្រទេសមួយទៀតនោះធ្វើឲ្យមានគ្រោះថ្នាក់ ភាពស្លុតរន្ធត់ ឬទុក្ខភ័យខ្លាំងពេក។
- ការពារព័ត៌មានសម្ងាត់របស់ជនរងគ្រោះដោយបង្កើតឲ្យមានការចែងថាការផ្សព្វផ្សាយឈ្មោះឬព័ត៌មានណាឲ្យគេស្គាល់អត្តសញ្ញាណរបស់ជនរងគ្រោះដោយគ្មានការអនុញ្ញាតិ ជាការល្មើសច្បាប់។

### តម្រុយៈ គាំទ្រជនរងគ្រោះនៅគ្រប់ដំហាននៃការរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មតាំងពីដើមដល់ចប់

រដ្ឋគួរផ្តល់ដល់ជនរងគ្រោះនូវព័ត៌មានពេញលេញក្នុងភាសាដែលជនរងគ្រោះយល់ អំពីជម្រើសទាំងឡាយដែលគេអាចជ្រើសយករួមទាំងការធ្វើជាសាក្សីក្នុងតុលាការ។ រដ្ឋក៏គួរព្យាយាមផ្តល់លទ្ធភាពដល់ជនរងគ្រោះក្នុងការទទួលសេវាពិគ្រោះនិងផ្តល់យោបល់ដើម្បីជួយឲ្យគេយល់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់គេ។

### តម្រុយៈ ដាក់វិធានការណ៍ការពារសម្រាប់ជនរងគ្រោះនិងសាក្សីនៃការជួញដូរជាកុមារ

រដ្ឋអាចពិចារណាបង្កើតវិធានការណ៍និងឧបករណ៍ជំនួយសាក្សីសម្រាប់ការពារជនងាយរងគ្រោះ ឲ្យមានដោយស្វ័យប្រវត្តសម្រាប់ជនរងគ្រោះជាកុមារ។ វិធីការពារបន្ថែមទៀតដែលអាចពិចារណាមានដូចជាការអនុញ្ញាតិឲ្យយកការថតវីដេអូនៃកិច្ចសម្ភាសន៍របស់ប៉ូលិសជាមួយជនរងគ្រោះជាកុមារ និង/ឬជាមួយសាក្សី ធ្វើជាភស្តុតាងរបស់ខ្លួន។ ប៉ុន្តែជនរងគ្រោះជាកុមារមិនគួរតម្រូវឲ្យចូលរួមទេ ជាពិសេសបើគេបានឆ្លងកាត់ភាពស្លុតរន្ធត់។

មានសេវាបណ្ដឹងរបស់រដ្ឋខ្លះប្រើជំនួយសាក្សីជាក់លាក់ឬភ្នាក់ងារទំនាក់ទំនងជនរងគ្រោះដើម្បីកាត់បន្ថយអារម្មណ៍ភិតភ័យនិងស្លុតរន្ធត់ដោយផ្ដល់ដល់ជនរងគ្រោះនូវព័ត៌មាននិងការគាំទ្រផ្ទាល់ ហើយនិងចូលទៅតុលាការជាមួយជនរងគ្រោះ។ អង្គការសង្គមស៊ីវិលអាចជួយផ្ដល់ធនធានយ៉ាងល្អក្នុងការជួយនិងគាំទ្របន្ថែមដល់ជនរងគ្រោះក្នុងរយៈកាលដំណើរការនៃការកាត់សេចក្ដីរបស់តុលាការ។

រដ្ឋទាំងឡាយអាចពិចារណាអនុញ្ញាតិឲ្យជនរងគ្រោះធ្វើដោយស្ម័គ្រចិត្តនូវសេចក្ដីថ្លែងអំពីផលប៉ះពាល់របស់ជនរងគ្រោះ នៅពេលតុលាការបានអនុម័តលើជនជាប់ចោទហើយ ហើយតុលាការកំពុងស្ថិតក្នុងពិធីដាក់កំណត់ទោសលើជនជាប់ចោទ គឺដើម្បីឲ្យតុលាការដឹងអំពីការខូចខាតដែលជនរងគ្រោះបានទទួល។ សេចក្ដីថ្លែងអំពីផលប៉ះពាល់របស់ជនរងគ្រោះអាចជួយជនរងគ្រោះក្នុងការធ្វើឲ្យសះស្បើយឡើងវិញ រួមទាំងដោយសារការដែលគេបានពន្យល់ចៅក្រមថាគេបានទទួលផលអាក្រក់យ៉ាងណាខ្លះទាំងផ្លូវកាយ ផ្លូវចិត្ត វិស័យថវិកានិង/ឬសង្គម។ សេចក្ដីថ្លែងអំពីផលប៉ះពាល់របស់ជនរងគ្រោះអាចមានប្រយោជន៍ក្នុង ៖

- ការកាត់បន្ថយការយល់របស់សាធារណជនថាជនរងគ្រោះមានភាពដាច់ពីគេក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មនោះ។
- ការបង្កើនឲ្យការកំណត់ទោសមានតម្លាភាពនិងឆ្លុះបញ្ចាំងការឆ្លើយតបរបស់សង្គមចំពោះឧក្រិដ្ឋកម្មនោះ។
- ការបង្កើនការធ្វើល្អឡើងវិញរបស់អ្នកជួញដូរដោយបង្ហាញអ្នកទាំងនោះនូវផលវិបាកពីអំពើល្មើសរបស់គេ។

រដ្ឋទាំងឡាយដែលមានបំណងប្រើប្រាសសេចក្ដីថ្លែងអំពីផលប៉ះពាល់របស់ជនរងគ្រោះ គួរចាត់ឲ្យមានការប្រយ័ត្ននានារួមទាំងការហាមដាក់កំហិតមិនឲ្យជនរងគ្រោះបញ្ចេញយោបល់អំពីភាពត្រឹមត្រូវនៃទោស ឬមិនឲ្យបញ្ចូលពាក្យដែលជេរប្រមាថ គំរាម បំភិតបំភ័យឬរុកគួនទៅក្នុងសេចក្ដីថ្លែងរបស់គេនោះ។ អ្នកជួញដូរក៏ត្រូវទទួលការអនុញ្ញាតិឲ្យអាចធ្វើតែស្ដសេចក្ដីថ្លែងអំពីផលប៉ះពាល់របស់ជនរងគ្រោះបានដែរ។

## តម្រុយ : ធ្វើយ៉ាងណាកុំឲ្យកម្មវិធីជំនួយនិងការពារក្លាយជាការជម្រុញឲ្យចូលរួម

គួរផ្ដល់កម្មវិធីជំនួយនិងការពារយ៉ាងណាកុំឲ្យក្លាយជាការបង្ខំ ដែលអាចធ្វើឲ្យខូចកម្មវិធីបណ្ដឹង។ អ្វីៗផ្ដល់ឲ្យសាក្សីឧទាហរណ៍ រួមទាំងកន្លែងស្នាក់នៅ ទិដ្ឋាការ គួរមានការកត់ត្រាទុកនិងមានការពិចារណាថាសមរម្យ ហើយការធ្វើបំពានខុសទាក់ទងនឹងកម្មវិធីគាំពារ ត្រូវកត់សំគាល់ហើយនិងដោះស្រាយជាបន្ទាន់។

## ការការពារក្រោយពីការកាត់សេចក្ដី

កម្មវិធីការពារមិនគួរឈប់នៅពេលពិធីកាត់សេចក្ដីចប់ទេ ប៉ុន្តែគួរសំអាងលើសេចក្ដីត្រូវការរបស់ជនរងគ្រោះម្នាក់ៗ។ បន្ទាប់ពីពិធីកាត់សេចក្ដីចប់ហើយភ្លាម មន្ត្រីជំនួយសាក្សីឬអាជ្ញាធរសមស្របដទៃគួរផ្ដល់ទៅជនរងគ្រោះនូវព័ត៌មានអំពីលទ្ធផលនៃការកាត់សេចក្ដីព្រមទាំងកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការកាត់សេចក្ដីនោះ រួមទាំងទម្ងន់ទោសដាក់លើអ្នកជួញដូរ កំឡុងពេលរបស់វា និងថ្ងៃដែលអ្នកជួញដូរនោះត្រូវដោះលែងវិញ ក៏ដូចជាសិទ្ធិនៃការប្ដឹងជំទាស់។ គេគួរពិនិត្យសើរើផែនការការពារជនរងគ្រោះយោងទៅតាមព័ត៌មានទាំងនោះដោយមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះហើយនិងការគិតពិចារណាអំពីការព្រួយបារម្ភរបស់គេ។

បន្ទាប់ពីការកាត់សេចក្ដីហើយ ការគំរាមនិងបំភិតបំភ័យលើជនរងគ្រោះពីការជួញដូរនិងក្រុមគ្រួសារនិងមិត្តភ័ក្តអាចកើនឡើង។ រដ្ឋគួរពិចារណាអំពីសេចក្ដីត្រូវការការការពារសាក្សីជារៀងរហូតហើយនិងវិធានការណ៍ផ្ដល់សុវត្ថិភាពផ្ទាល់ខ្លួនរួមទាំងការអនុញ្ញាតិឲ្យជនរងគ្រោះបន្តស្នាក់នៅរហូតលើដែនដីនៃយុត្តាធិការនោះបើសិនជនរងគ្រោះនឹងមានគ្រោះថ្នាក់ពេលត្រឡប់ទៅប្រទេសដើមខ្លួនវិញ។[23] លើសពីគ្រោះថ្នាក់បណ្ដាលពីការសងសឹកឬការធ្លាក់ចូលក្នុងសកម្មភាពនៃការជួញដូរឡើងវិញ ការវាយតម្លៃទំហំហានិភ័យបង្កដោយការការពារនិងការគាំទ្រមិនគ្រប់គ្រាន់នៅក្នុងរដ្ឋដើម អាចជាការត្រឹមត្រូវសម្រាប់ការសម្រេចថាតើគួរបញ្ជូនជនរងគ្រោះត្រឡប់ទៅប្រទេសដើមវិញឬក៏ការផ្ដល់សិទ្ធិរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសដែលមានធ្វើការកាត់ទោសនោះឬប្រទេសណាមួយផ្សេងទៀតជាការប្រសើរជាង។[24]

[23] ចូរមើលផ្នែក ៣៣ ខាងក្រោមស្ដីអំពី ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារ

[24] ចូរមើលផ្នែក ៣៣ ខាងក្រោមស្ដីអំពី ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារ
ចូរមើលការបញ្ចេញមតិលើគោលការណ៍ជាអនុសាសន៍និងសេចក្ដីណែនាំស្ដីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស
(Commentary to the Recommended Principles and Guidelines on Human Rights and Human Trafficking) OHCHR, ឆ្នាំ២០១០ ទំព័រ ១៨០-១៨២

## ២.៣. ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារ

ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារ**ចាប់ផ្ដើមនៅចំណុចនៃការជួបគ្នាដំបូង** ដែលនៅពេលនោះមានធ្វើការវាយតម្លៃសេចក្ដីត្រូវការរបស់ជនគេជួញដូរដោយពិនិត្យសេចក្ដីត្រូវការបន្ទាន់ ដូចជាកន្លែងស្នាក់នៅបណ្ដោះអាសន្ន ការមើលថែដោយពេទ្យ សុវត្ថិភាពនិងសន្តិសុខ។ កិច្ចការទាំងនេះអាចធ្វើនៅរដ្ឋដើម រដ្ឋកណ្ដាល ឬរដ្ឋទីដៅ។ ដំណោះស្រាយក្នុងការការការពារ ទាក់ទងនឹងការយកជនរងគ្រោះចេញពីការគ្រប់គ្រងរបស់អ្នកជួញដូរ ហើយកាត់បន្ថយហានិភ័យបន្ទាន់។ ចំណែកឯដំណោះស្រាយក្នុងការការការពារដែលមានចីរភាពវិញមានភាពពេញលេញ គឺលើសពីការដោះស្រាយសេចក្ដីត្រូវការបន្ទាន់ ឈានទៅដល់ការជួយជនរងគ្រោះពីការជួញដូរឲ្យមានជំហរខ្លួនឯងឡើងវិញនិងធ្វើឲ្យមានលទ្ធភាពរួមរស់ក្នុងសង្គមថ្មីឬសង្គមដើមវិញ។

ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារអាចមានបញ្ចូលវិធានការណ៍ដែលធ្វើឲ្យជនរងគ្រោះមានលទ្ធភាពទទួលឱកាសយូរអង្វែងក្នុងការប្រយុទ្ធឈ្នះនឹងបញ្ហាដែលធ្វើឲ្យគេធ្លាក់ចូលក្នុងការជួញដូរនៅលើកដំបូង។ ឧទាហរណ៍ ដូចជាការអាចទទួលបានការសិក្សា ការហាត់រៀន សកម្មភាពសម្រាប់ទ្រទ្រង់ជីវិត និងឱកាសមានការងារធ្វើ ជាសេវាដែលដោះស្រាយបញ្ហាងាយរងគ្រោះនិងគាំទ្រសមាហរណកម្មសង្គមនិងសេដ្ឋកិច្ចរបស់ជនរងគ្រោះ។ ដំណោះស្រាយដែលបានអនុវត្តនៅពេលជួបគ្នាដំបូងអាចត្រូវការឲ្យមានបន្តទៀតឬពិនិត្យដោះស្រាយជានិច្ច ដូចជាកន្លែងស្នាក់នៅ សេវាពេទ្យនិងចិត្តសាស្ត្រហើយនិងសេវាពិគ្រោះនិងផ្ដល់យោបល់ ហើយនិងការធានាសុវត្ថិភាពនិងសន្តិសុខឲ្យជនរងគ្រោះ។

វត្ថុបំណងចុងបញ្ចប់នៃកម្មវិធីផ្ដល់ជំនួយនិងការការពារដល់ជនរងគ្រោះគឺដើម្បីធ្វើយ៉ាងណាឲ្យជនរងគ្រោះពីការជួញដូរ អាចទ្រាំទ្រអ្វីៗដែលគេបានឆ្លងកាត់ ចិញ្ចឹមជីវិតខ្លួនបាន ហើយនិងដើម្បីចូលរួមយ៉ាងពេញលេញក្នុងកិច្ចការរស់នៅទាំងសេដ្ឋកិច្ចទាំងសង្គម។ ការពុំអាចបំពេញវត្ថុបំណងនេះអាចបង្កើនភាពងាយរងគ្រោះហើយអាចធ្វើឲ្យធ្លាក់ក្នុងកងចក្រនៃការក្លាយជាជនរងគ្រោះម្ដងហើយម្ដងទៀត។

ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារមានភាពស្មុគ្រស្មាញកាន់តែខ្លាំងបើការជួញដូរធ្វើឡើងឆ្លងប្រទេស ហើយជំនួយនិងការការពារជនរងគ្រោះត្រូវមានការសម្របសម្រួលរវាងនិងក្នុងចំណោមអាជ្ញាធរនិងអ្នកផ្ដល់សេវារបស់រដ្ឋពីរឬលើស។ ក្រោយពីឱកាសពិចារណាឬបណ្ដឹងរកយុត្តិធម៌បានចប់ហើយ គេគួរពិនិត្យនិងពិចារណាអំពីជម្រើស ឬមួយបញ្ចូលឲ្យរួមរស់ក្នុងសង្គមថ្មី ត្រឡប់ទៅវិញដោយស្ម័គ្រចិត្ត ឬរួមរស់ក្នុងសង្គមចាស់ឡើងវិញ។[25] ជនរងគ្រោះអាចត្រឡប់ទៅសហគមន៍ដើមខ្លួនវិញ លើកលែងតែគេទទួលបានសិទ្ធិឬទិដ្ឋាការរស់នៅជាអចិន្ត្រៃយ៍ឬបញ្ជូនទៅរដ្ឋទី៣។ ក្នុងករណីដែលជនរងគ្រោះត្រូវបានបញ្ជូនទៅកន្លែងដើមវិញ ទោះបីជាក្នុងរដ្ឋតែមួយឬរដ្ឋផ្សេង អជ្ញាធរគួរធ្វើយ៉ាងណាឲ្យគេទទួលបានការការពារអំពីការសងសឹកឬធ្លាក់ចូលទៅក្នុងការជួញដូរឡើងវិញទៀតនៅពេលទៅដល់ឬក្នុងពេលចូលរួមរស់ក្នុងសហគមន៍។

ការត្រឡប់ទៅ**ប្រទេសដើមវិញ**គួរ តាមដែលអាចធ្វើបាន ជាការធ្វើដោយស្ម័គ្រចិត្ត ហើយធ្វើឡើងដោយមានការគិតអំពីសិទ្ធិ សុវត្ថិភាព និងភាពថ្លៃថ្នូររបស់អ្នកវិលត្រឡប់ រួមទាំងការផ្ដល់ការការពារ ជំនួយនិងការគាំទ្រគ្រប់គ្រាន់ចាំបាច់ក្នុងការឲ្យគេរួមរស់ក្នុងសហគមន៍ហើយនិងការពារកុំឲ្យចូលក្នុងការជួញដូរឡើងវិញទៀត។[26] បើការបញ្ជូនជនរងគ្រោះទៅ**រដ្ឋទី៣** ជាការប្រសើរជាង រដ្ឋទី៣នោះគួរជួយក្នុងការសម្រួលការផ្ទេរទីកន្លែងនិងការរួមរស់ក្នុងសហគមន៍ប្រកបដោយសុវត្ថិភាព។[27] បើនៅតែមានសេចក្ដីបារម្ភអំពីសុវត្ថិភាពជារៀងរហូត វិស័យមនុស្សធម៌ឬក៏ហានិភ័យផ្សេងៗទៀតធ្វើឲ្យការបញ្ជូនជនរងគ្រោះត្រឡប់ទៅវិញមិនបាន គួរពិចារណាផ្ដល់សិទ្ធិរស់នៅជាបណ្ដោះអាសន្នឬអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។[28]

25 គោលការណ៍ជាអនុសាសន៍និងសេចក្ដីណែនាំស្ដីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស (Recommended Principles and Guidelines on Human Rights and Human Trafficking (E/2002/68/Add.1), អគ្គស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្ដីណែនាំ ៥(៨)

26 គោលការណ៍ជាអនុសាសន៍និងសេចក្ដីណែនាំស្ដីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស (Recommended Principles and Guidelines on Human Rights and Human Trafficking (E/2002/68/Add.1), អគ្គស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្ដីណែនាំ ៦(៨)។ ចូរមើលផងដែរ ប្រការ ៨(៣)-(៤) ប្រការ ៩(១)(ខ) នៃពិធីការនៃការជួញដូរមនុស្សទាក់ទាងទៅនឹងការវិលត្រឡប់វិញដោយសុវត្ថិភាព

27 គោលការណ៍ជាអនុសាសន៍និងសេចក្ដីណែនាំស្ដីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស (Recommended Principles and Guidelines on Human Rights and Human Trafficking (E/2002/68/Add.1), អគ្គស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សេចក្ដីណែនាំ ៦(៨)។ ចូរមើលផងដែរ ប្រការ ៨(៣)-(៤) ប្រការ ៩(១)(ខ) នៃពិធីការនៃការជួញដូរមនុស្សទាក់ទាងទៅនឹងការវិលត្រឡប់វិញដោយសុវត្ថិភាព

28 ចូរមើលការបញ្ចេញមតិលើគោលការណ៍ជាអនុសាសន៍និងសេចក្ដីណែនាំស្ដីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស
(Commentary to the Recommended Principles and Guidelines on Human Rights and Human Trafficking)
OHCHR, ឆ្នាំ២០១០ ទំព័រ ១៨០-១៨២

ដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារត្រូវការ**ការសហការ**ពីអ្នកផ្តល់សេវានិងអ្នកមានតួនាទី។ ការបញ្ជូនព័ត៌មាននិងចម្លើយទៅវិញទៅមកជាកត្តាសំខាន់ជាទីបំផុតក្នុងការធានាឲ្យសេវានានាមានភាពសមស្របនិងផ្តល់ត្រូវទៅតាមពេលវេលាហើយនិងមាននៅក្នុងរដ្ឋដើមនិងរដ្ឋទីដៅ។ ការសហការនិងការចូលរួមពីជនរងគ្រោះក្នុងកិច្ចការនេះជាការសំខាន់។ ជនរងគ្រោះមិនមែនគ្រាន់តែគួរយល់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនក្នុងការអនុវត្តផែនការការពារប៉ុណ្ណោះទេ ប៉ុន្តែយោបល់របស់គេអំពីប្រភេទនៃជំនួយនិងការគាំទ្រដែលគួរផ្តល់ជាកត្តាដ៏សំខាន់បំផុតដើម្បីឲ្យផែនការយូរអង្វែងបានជោគជ័យ។ ត្រូវមានគិតអំពីសេចក្តីត្រូវការនិងសេចក្តីប្រាថ្នារបស់ជនម្នាក់ៗក្នុងការបង្កើតផែនការការពារនានា ជាពិសេសក្នុងករណីកុមារដែលផលប្រយោជន៍របស់គេជាចំណុចសំខាន់ទី១ក្នុងផែនការការពារនានា។ ជាទីបញ្ចប់ ផែនការជំនួយនិងការពារគួរពិនិត្យនិងវាយតម្លៃយូរៗម្តង ហើយនិងកែសម្រួលទៅតាមការផ្លាស់ប្តូរនៃតម្រូវការរបស់ជនរងគ្រោះពីការជួញដូរ។

### តារាង ទី១ ផ្នែកសំខាន់ៗនៃដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារ

| | |
|---|---|
| សេចក្តីត្រូវការចាំបាច់ | • កន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាពនិងជានិរន្ត ជាពិសេសនៅពេលការរួមរស់ក្នុងសហគមន៍ពុំទាន់គួរធ្វើ<br>• វិធានការណ៍សុវត្ថិភាពនិងសន្តិសុខ |
| ការថែទាំក្នុងវិស័យពេទ្យនិងចិត្តសាស្ត្រសង្គម | • ការពិគ្រោះនិងផ្តល់យោបល់ក្នុងវិស័យចិត្តសាស្ត្រ<br>• ការពិគ្រោះនិងផ្តល់យោបល់ក្នុងវិស័យសង្គម រួមទាំងការទៅលេងបងប្អូន<br>• ការពិនិត្យពេទ្យនិងពេទ្យធ្មេញ<br>• អន្តរាគមន៍ក្នុងការរួមរស់ក្នុងគ្រួសារនិងក្នុងសហគមន៍ឡើងវិញ |
| សមាហរណកម្មសេដ្ឋកិច្ច | • ការសិក្សា ជាពិសេសសម្រាប់កុមារ<br>• ការរៀនភាសាក្នុងករណីបញ្ចូលទៅក្នុងសង្គម<br>• ការរៀនជំនាញផ្អែកលើសេចក្តីត្រូវការរបស់ទីផ្សារឬឧស្សាហកម្ម<br>• ជំនួយក្នុងការរកការងារ<br>• ជំនួយថវិកាសម្រាប់ទ្រទ្រង់ជីវិតនិងការជួយណែនាំ<br>• ជំនួយថវិកាសម្រាប់ធ្វើទុនដំបូង |
| ជំនួយនិងការឧបត្ថមក្នុងវិស័យច្បាប់ | • ការពិគ្រោះនិងផ្តល់យោបល់ក្នុងវិស័យច្បាប់<br>• ការបំពេញពាក្យបណ្តឹងអំពីឧក្រិដ្ឋកម្មនិងការសុំសំណងជទែទៀតនៅមុខអាជ្ញាធរអនុវត្តច្បាប់និង/ឬរដ្ឋអាជ្ញា<br>• ជំនួយក្នុងការទារប្រាក់សំណង<br>• ជំនួយក្នុងការដាក់ពាក្យសុំសិទ្ធិរស់នៅជាបណ្តោះអាសន្នឬអចិន្ត្រៃយ៍បើមាន<br>• ការសុំដោះលែងជនរងគ្រោះពីការជួញដូរពីឧក្រិដ្ឋកម្មដែលបានធ្វើដោយសារជាលទ្ធផល |

### សំណង

មធ្យោបាយដ៏ចំបងមួយក្នុងការសម្រួលឲ្យមានដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារគឺការផ្តល់សំណង ជំនួយថវិកា ឬសំណងដែលជាការទទួលស្គាល់នូវរបួស ការបាត់បង់ឬការខូចខាតទទួលរងដោយជនរងគ្រោះពីការជួញដូរ។ ទោះបីសំណងមិនធ្វើឲ្យបទពិសោធន៍នៃការជួញដូររបស់ជនរងគ្រោះបកត្រឡប់ក្រោយបានទេ ប៉ុន្តែវាអាចបង្កើនការស្តារមកវិញហើយការពារគេដោយថវិកាកុំឲ្យងាយធ្លាក់ចូលក្នុងការជួញដូរឡើងវិញទៀត។ សំណងអាចមានគិតបញ្ចូលបៀវត្តដែលពុំបានបើក ថ្លៃសេវាច្បាប់ ថ្លៃពេទ្យ ការបាត់បង់ឱកាស ហើយនិងសំណងចំពោះការឈឺចាប់និងទុក្ខវេទនាដែលបានរង។[30]

[29] សម្រាប់ព័ត៌មានបន្ថែមអំពីការមិនគិតជាឧក្រិដ្ឋកម្ម ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការធ្វើឲ្យការជួញដូរមនុស្សទៅជាឧក្រិដ្ឋកម្ម *(Policy Guide on Criminalizing Trafficking in Persons),* នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ២០១៤ ទំព័រ ៧.

[30] ចូរមើលផងដែរ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីគោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌សម្រាប់ជនរងគ្រោះពីឧក្រិដ្ឋកម្មនិងការប្រើអំណាចខុស (UN *Declaration of Basic Principles of Justice for Victims of Crime and Abuse of Power),* A/RES/40/34 វិច្ឆិកា ឆ្នាំ១៩៨៥ (ប្រការ ១២ និង១៣)

កម្មវិធីសំណងសម្រាប់ជនរងគ្រោះពីការជួញដូរអាចយកចេញពីទ្រព្យសម្បត្តិរបស់អ្នកជួញដូរឬពីដុំប្រាក់របស់រដ្ឋដែលមានការចាត់ចែងតាមរយៈនីតិវិធីច្បាប់ឬសកម្មភាពរដ្ឋបាល។ ក្នុងយុត្តាធិការជាច្រើន គេភ្ជាប់ពាក្យបណ្តឹងរដ្ឋប្បវេណីសម្រាប់ការខូចខាតនានាជាមួយនឹងបណ្តឹងព្រហ្មទ័ណ្ឌ ហើយសំណងជាប្រាក់ត្រូវបានដាក់ក្នុងការអនុម័តរបស់តុលាការ ឬការបង់សំណងទៅជនរងគ្រោះជាផ្នែកមួយនៃទោសពិន័យ។ ក្នុងយុត្តាធិការដទៃទៀត គេអនុញ្ញាតិឲ្យមានការទារសំណងតាមបណ្តឹងរដ្ឋប្បវេណីដែលដាច់ដោយឡែកពីបណ្តឹងព្រហ្មទ័ណ្ឌ។ បណ្តឹងតាមរយៈតុលាការពលកម្មសម្រាប់បៀវត្តមិនទាន់បានទទួលនិងផលពីកិច្ចព្រមព្រៀងនានា ជាពិសេសក្នុងករណីជួញដូរដើម្បីកេងប្រវ័ញ្ច ក៏ជាផ្លូវដែលអាចធ្វើដើម្បីទទួលសំណង។

ប្រទេសខ្លះក្នុងដំបន់អាស៊ីប៉ាស៊ីហ្វិកបានបង្កើតមូលនិធិដោយប្រើធនធានរដ្ឋដើម្បីផ្តល់ជំនួយជាសម្ភារៈដល់ជនរងគ្រោះពេលគេបានចេញផុតពីការជួញដូរ។ មូលនិធិថវិកាសម្រាប់ជនរងគ្រោះក៏មានបង្កើតដោយការយកប្រាក់ពីការពិន័យដែលជាលទ្ធផលនៃការកាត់ទោសជនឧក្រិដ្ឋ។ ឯប្រទេសដទៃទៀតអនុញ្ញាតិឲ្យជនរងគ្រោះមានលទ្ធភាពទទួលថវិកាពីដុំថវិកាសម្រាប់ជំនួយទូទៅដែលមានហើយ ដូចជាដុំថវិកាសម្រាប់ជនរងគ្រោះពីឧក្រិដ្ឋកម្មឬអំពើហិង្សាធ្ងន់ធ្ងរ។

អ្នកនៅក្នុងវិស័យឯកជនដែលអាចមានឧស្សាហកម្មឬពាណិជ្ជកម្មផ្គត់ផ្គង់សម្ភារៈប៉ះពាល់ដោយការជួញដូរ ក៏មានតួនាទីក្នុងការការពារបុគ្គលឹកពីការកេងប្រវ័ញ្ចហើយនិងផ្តល់សំណងទៅជនរងគ្រោះ។ ដូចនេះហើយ ថវិការដ្ឋក៏អាចបានបន្ថែមពីវិភាគទានរបស់ស្ថាប័នរដ្ឋ អង្គការមនុស្សធម៌ ពាណិជ្ជករហើយនិងឯកជន។

យុត្តាធិការភាគច្រើនអនុញ្ញាតិឲ្យជនរងគ្រោះប្តឹងរកសំណងតាមរយៈតុលាការរដ្ឋប្បវេណី (តាមរយៈប្រាក់សង្គមកិច្ចឬកម្មវិធីពលកម្ម) ប៉ុន្តែទេសន្តរជនដែលមានឋានៈមិនប្រក្រតីអាចមានឧបស័គ្គក្នុងការទទួលបាននូវសំណងទាំងនោះដោយសារឋានៈរបស់គេនិង/ឬកង្វះឯកសារ។ ដូច្នេះហើយ រដ្ឋនានាគួរសម្រួលផ្តល់លទ្ធភាពដល់ជនរងគ្រោះក្នុងការប្តឹងតាមរយៈតុលាការរដ្ឋប្បវេណីដើម្បីទទួលសំណងសម្រាប់ការខូចខាតដែលគេបានទទួល រួមទាំងជនរងគ្រោះដែលមានឋានៈមិនប្រក្រតី។

រូបខាងក្រោមនេះបង្ហាញប្រភពសំណងសម្រាប់ជនរងគ្រោះដែលអាចរកបាន។

### រូបទី១ ប្រភពសំណងសម្រាប់ជនរងគ្រោះដែលអាចរកបាន




## តម្រុយៈ ផ្តល់សំណងដែលមានប្រសិទ្ធិភាពសម្រាប់ជាផ្នែកមួយនៃដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារ

រដ្ឋនានាគួរពិចារណាបង្កើតប្រភពនៃប្រាក់សំណងសម្រាប់ជនរងគ្រោះពីការជួញដូរក្រៅពីតាមរយៈបណ្តឹងព្រហ្មទ័ណ្ឌ។ គួរធ្វើការពិចារណាធ្វើយ៉ាងណាឲ្យជនរងគ្រោះដែលមិនមានសញ្ជាតិមានលទ្ធភាពទទួលបានសំណងផង។

# ផ្នែកទី ៣:

## ការសម្របសម្រួលហើយនិងរបៀបរបបពហុអង្គភាព

## ៣.១. អង្គភាពនានាដែលមានតួនាទីក្នុងការការពារ

ការសម្របសម្រួលជាផ្នែកមួយយ៉ាងសំខាន់នៃការការពារពេញលក្ខណៈ។ ដោយសេចក្តីត្រូវការរបស់ជនរងគ្រោះពីការជួញដូរក្នុងវិស័យការការពារមានភាពស្មុគស្មាញ កម្មវិធីដែលអាចបត់បែននិងមានប្រសិទ្ធិភាពជាងគេត្រូវមានអ្នកជំនាញហើយនិងអន្តរាគមន៍មួយចំនួន។ កាតព្វកិច្ចក្នុងការការពារជនរងគ្រោះពីការជួញដូរ ជាចំបងស្ថិតនៅលើរដ្ឋ ប៉ុន្តែអង្គភាពផ្សេងៗទៀតអាចដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រមុខនាទីនេះ។[31] សង្គមស៊ីវិលស្ថិតនៅចំចំណុចយ៉ាងល្អក្នុងការកសាងទំនុកទុកចិត្តរវាងជនរងគ្រោះពីការជួញដូរនិងអាជ្ញាធរនានា ហើយមានជំនាញជាក់លាក់ដែលចាំបាច់សម្រាប់ផ្តល់សេវាការពារប្រកបដោយប្រសិទ្ធិភាព។

ពិធីការនៃការជួញដូរមនុស្សទទួលស្គាល់ភាពចាំបាច់នៃការសម្របសម្រួលរវាងអង្គភាពច្រើនក្នុងកម្មវិធីផ្តល់ជំនួយនិងការពារហើយតម្រូវឲ្យរដ្ឋទាំងឡាយពិចារណាអនុវត្តវិធានការណ៍ដើម្បីធ្វើឲ្យជនរងគ្រោះពីការជួញដូរបានសះស្បើយតាមផ្លូវកាយ ចិត្តនិងសង្គម *ដោយការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការផ្សេងៗទៀត និងអង្គភាពផ្សេងៗទៀតនៃសង្គមស៊ីវិល។*[32] អង្គភាពរដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាលមួយចំនួនអាចមានការពាក់ព័ន្ធក្នុងការការពារជនរងគ្រោះ រួមទាំងប៉ូលិស អាជ្ញាធរអន្តោប្រវេសន៍និងអាជ្ញាធរសង្គមកិច្ច ក៏ដូចជាអង្គភាពទាក់ទងនឹងពលកម្មនិងឧស្សាហកម្ម ក្រសួងមហាផ្ទៃនិងការបរទេស និងអង្គការក្រៅរដ្ឋាភិបាលដែលមានជំនាញខាងការផ្តល់សេវាសម្រាប់ជនរងគ្រោះពីឧក្រិដ្ឋកម្ម ទេសន្តរជន ស្ត្រីនិងឬកុមារ ក៏ដូចជាអ្នកផ្តល់សេវាជំនួយច្បាប់។[33]

### ការផ្តល់ជំនួយផ្ទាល់និងអង្គភាពដែលមានតួនាទីការពារ

អង្គភាពរដ្ឋជាអ្នកទទួលបន្ទុកក្នុងការផ្តល់ការការពារដល់ជនរងគ្រោះ ហើយអាចផ្តល់ការឧបត្ថមជាប្រាក់ផ្ទាល់តាមរយៈកម្មវិធីសេវាសង្គម សេវាថែកុមារ មូលនិធិថវិកាបណ្តឹងព្រហ្មទ័ណ្ឌ មូលនិធិថវិកាជនរងគ្រោះ ថវិកាសម្រាប់ស្ត្រីដែលឆ្លងកាត់អំពើហិង្សាឬប្រភពនានាដទៃទៀត។ អង្គភាពរដ្ឋខាងក្រោមនេះមានសារៈសំខាន់ពិសេស ៖

- ប៉ូលិសនិងអាជ្ញាធរយុត្តិធម៌ព្រហ្មទ័ណ្ឌសំខាន់ណាស់សម្រាប់សុវត្ថិភាពផ្លូវកាយរបស់ជនរងគ្រោះ
- អាជ្ញាធរអន្តោប្រវេសន៍និងកុងស៊ុលអាចមានការទាក់ទងក្នុងការសម្រួលការស្នាក់នៅជាបណ្តោះអាសន្នឬអចិន្ត្រៃយ៍ឲ្យជនរងគ្រោះក្នុងរដ្ឋនោះ។
- ភ្នាក់ងារសេវាសុខាភិបាលរដ្ឋអាចផ្តល់ជំនួយក្នុងវិស័យពិគ្រោះនិងផ្តល់យោបល់ ពត៌មាន ពេទ្យ ចិត្តិសាស្ត្រ និងសម្ភារៈ
- ភ្នាក់ងារផ្តល់សេវាសង្គមរដ្ឋក៏មានតួនាទីក្នុងការផ្តល់ការសិក្សានិងការបង្ហាត់បង្រៀនជំនាញ ហើយនិងក្នុងការដកចេញនូវរបាំងនានាដើម្បីផ្តល់លទ្ធភាពឲ្យជនរងគ្រោះទទួលបាននូវឱកាសការងារ សិក្សាធិការ និងការហាត់រៀនជំនាញ។[34]



[31] ចូរមើល *ពិធីការនៃការជួញដូរមនុស្ស* ( *Trafficking in Persons Protocol*) ប្រការ ៦( ៣ )

[32] ចូរមើល *ពិធីការនៃការជួញដូរមនុស្ស* (*Trafficking in Persons Protocol*) ប្រការ ៦( ៣ )

[33] សម្រាប់ពត៌មានបន្ថែម ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ (*Policy Guide on Identifying Victims of Trafficking) នីតិវិធីក្រុងបាលី ( Bali Process)* ផ្នែក ៣.១.

[34] ចូរមើល ប្រការ ៦នៃពិធីការនៃការជួញដូរមនុស្ស (*Trafficking in Persons Protocol)*

ទោះបីអង្គភាពរដ្ឋទទួលបន្ទុកក្នុងការផ្តល់ការការពារដល់ជនរងគ្រោះ ក្នុងរដ្ឋជាច្រើនអង្គភាពមិនមែនរដ្ឋ រួមទាំងអង្គការសង្គមស៊ីវិល អង្គការអន្តរជាតិនិងអ្នកផ្តល់សេវាមិនមែនរដ្ឋនានាឯទៀត ជារឿយៗធ្វើការការពារក្រោមសម្ពាធថវិកានិងសម្ពាធដទៃទៀត។

- អង្គការក្រៅរដ្ឋាភិបាលនិងអង្គការអន្តរជាតិអាចជួយអង្គភាពរដ្ឋក្នុងការផ្តល់ជនរងគ្រោះនូវពត៌មានអំពីសេវាជំនាញនានារបស់រដ្ឋ។
- គេក៏អាចផ្តល់ជំនួយសម្ភារៈក្នុងលក្ខណៈជាកន្លែងស្នាក់នៅ អាហារ សេវាសុខភាព(រួមទាំងសេវាសុខភាពផ្លូវភេទ ) ក៏ដូចជាការពិគ្រោះនិងផ្តល់យោបល់ក្នុងវិស័យផ្លូវចិត្ត ការណែនាំក្នុងវិស័យច្បាប់និងអន្តោប្រវេសន៍។ យោងតាមការទទួលខុសត្រូវរបស់ខ្លួនក្នុងការការពារ រដ្ឋគួរផ្តល់ដល់សង្គមស៊ីវិលនូវការគាំទ្រនិងថវិកាគ្រប់គ្រាន់ដើម្បីការពារជនរងគ្រោះ។[35]
- អង្គការអន្តរជាតិដូចជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិ និង IOM អាចផ្តល់ការគាំទ្រជាថវិកានិងសម្ភារៈ។ [36]

## អង្គភាពដែលមានតួនាទីក្នុងការបញ្ជូនទៅវិញនិងសមាហរណ័កម្ម

អង្គភាពទាក់ទងនឹងការបញ្ជូនជនរងគ្រោះទៅប្រទេសដើមរបស់គេវិញអាចរួមមានអាជ្ញាធរអន្តោប្រវេសន៍និងការបរទេស ប៉ូលិសកិច្ចការកុងស៊ុល ក្រសួងសង្គមកិច្ច ក៏ដូចជាអាជ្ញាធរនានាឯទៀតនៅក្នុងប្រទេសដើមនិងប្រទេសទីដៅ។ អង្គភាពទាំងនេះ ទាំងនៅក្នុងរដ្ឋបញ្ជូននិងទាំងនៅក្នុងរដ្ឋទទួល អាចត្រូវការចេញឲ្យជនរងគ្រោះនូវឯកសារដែលគេត្រូវការក្នុងការវិលត្រឡប់វិញ។[37] ទីស្នាក់នៅរបស់រដ្ឋឬអ្នកផ្តល់សេវាស្នាក់នៅបណ្តោះអាសន្ន ទាំងនៅក្នុងរដ្ឋបញ្ជូនទាំងនៅក្នុងរដ្ឋទទួល ត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នាជាប់ជានិច្ច។ អង្គភាពពីរដ្ឋទាំងពីរក៏ត្រូវធ្វើការសម្របសម្រួលជាមុនដើម្បីបង្កើតនិងអនុវត្តផែនការសម្រាប់បញ្ចូលជនដែលវិលត្រឡប់ទៅវិញទៅក្នុងសង្គម។ ឧទាហរណ៍ក្រសួងពលកម្មនិងការងារនិងឧស្សាហកម្មអាចដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ឱកាសឲ្យជនរងគ្រោះមានលទ្ធភាពរកចិញ្ចឹមជីវិតដោយចីរភាពនិងរួមរស់ក្នុងសង្គមឡើងវិញ។

អង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងការបញ្ជូនទៅវិញនិងសមាហរណ័កម្មអាចរួមមានក្រុមគាំទ្រសម្រាប់ជនរងគ្រោះ ទេសន្តរជនស្ត្រីនិងកុមារ។ អង្គការអន្តរជាតិដូចជា IOM និងភ្នាក់ងារអង្គការសហប្រជាជាតិ អាចដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រឬតាមមើលដំណើរវិលត្រឡប់ ហើយនិងសម្រួលការសហការរវាងរដ្ឋនានាហើយនិងកសាងផែនការការពារនិងបញ្ចូលជនរងគ្រោះទៅក្នុងសង្គមប្រកបដោយចីរភាព។[38] អង្គភាពមិនមែនរដ្ឋាភិបាលនិងអន្តររដ្ឋាភិបាលទាំងនោះអាចសកម្មក្នុងការសម្រួលការសហការរវាងរដ្ឋបញ្ជូននិងរដ្ឋទទួលដែលផ្តល់ជំនួយទាំងមុនពេលចេញដំណើរនិងក្រោយពីការវិលត្រឡប់។

---

[35] ចូរមើល *កូនសៀវភៅស្តីអំពីជំនួយចំពោះជនរងគ្រោះពីការជួញដូរ* (*The IOM Handbook on Direct Assistance to Victims of Trafficking*) IOM, 2007, ជំពូកទី៤ និងយន្តការជាតិនៃការបញ្ជូនឈ្មោះ រួមកម្លាំងដើម្បីការពារសិទ្ធិរបស់ជនដែលគេជួញដូរ (*National Referral Mechanisms, Joining efforts to protect the Rights of Trafficked Persons: A Practical Handbook*) កូនសៀវភៅសម្រាប់អនុវត្ត OSCE ឆ្នាំ ២០០៤ ទំព័រ ៧៣-៧៦

[36] តាមរយៈ ថវិកាជំនួយសម្រាប់ពិភពលោក (Global Assistance Fund (GAF) និងយន្តការនៃការគាំទ្រដទៃទៀតនៅថ្នាក់ជាតិ និងតំបន់ (IOM) ផ្តល់ជំនួយផ្ទាល់ទៅជនរងគ្រោះពីការជួញដូរប្រមាណ ៦០០០–៧០០០ នាក់ក្នុងមួយឆ្នាំៗ

[37] ស្ថានទូតនិងកុងស៊ុលនានាដែលចេញឯកសារជំនួសឯកសារចាស់សម្រាប់ការធ្វើដំណើរ មិនត្រូវដាក់ជននោះថាជាជនរងគ្រោះពីការជួញដូរនៅក្នុងឯកសារទាំងនោះឡើយ ហើយអជ្ញាធរចាត់ចែងកិច្ចការនៃការវិលត្រឡប់ មិនគួរបញ្ជូនពត៌មានផ្ទាល់ខ្លួនរបស់ជនរងគ្រោះទៅប្រទេសដើមដោយគ្មានការអនុញ្ញាតិដោយជាក់ច្បាស់ពីសមីខ្លួនឡើយ

[38] ចូរមើល *កូនសៀវភៅរបស់អង្គការអន្តរជាតិសម្រាប់ទេសន្តរជនស្តីអំពីជំនួយផ្ទាល់ចំពោះជនរងគ្រោះពីការជួញដូរ* (*The IOM Handbook on Direct Assistance to Victims of Trafficking*) IOM,*ឆ្នាំ២០០៧ ជំពូក៣ និងយន្តការជាតិនៃការបញ្ជូនឈ្មោះ រួមកម្លាំងដើម្បីការពារសិទ្ធិរបស់ជនដែលគេជួញដូរ* (*National Referral Mechanisms, Joining efforts to protect the Rights of Trafficked Persons: A Practical Handbook*) កូនសៀវភៅសម្រាប់អនុវត្ត OSCE ឆ្នាំ ២០០៤ ទំព័រ ៨០-៨៣

## ៣.២. ការសម្របសម្រួលថ្នាក់នយោបាយ

ការសម្របសម្រួលថ្នាក់នយោបាយត្រូវមានដើម្បីបានជាមូលដ្ឋានសម្រាប់ការសម្របសម្រួលដែលមានប្រសិទ្ធិភាពរវាងអង្គភាពទាំងឡាយដែលមានតួនាទីក្នុងវិស័យការពារ។ មានការប្តេជ្ញានយោបាយជាច្រើនបានធ្វើក្នុងកំរិតអន្តរជាតិ តំបន់ និងជាតិ ហើយកិច្ចព្រមព្រៀងក៏មានរួចជាស្រេចសម្រាប់សម្របសម្រួលការឆ្លើយតបនានា។
នៅថ្នាក់អន្តរជាតិ រដ្ឋទាំងឡាយបានប្តេជ្ញាទទួលកាតព្វកិច្ចមាំៗតាមការចូលធ្វើជាភាគីនៃពិធីការក្នុងការជួញដូរមនុស្ស។ លើសពីនេះទៀត ការប្តេជ្ញាយ៉ាងមាំក្នុងថ្នាក់ដំបន់ក៏ត្រូវបានធ្វើ។ ឧទាហរណ៍ សមាជិកនៃអាស៊ានបានព្រមព្រៀង*ចេញសេចក្តីប្រកាសប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ។*

> **តម្រុយៈ ធ្វើយន្តការសម្របសម្រួលជាតិសម្រាប់ការពារជនរងគ្រោះពីការជួញដូរឲ្យទៅជាផ្លូវការ**
>
> យន្តការសម្របសម្រួលជាតិអាចមានប្រសិទ្ធិភាពជាងបើមានកិច្ចព្រមព្រៀងជាផ្លូវការ ឧទាហរណ៍ តាមរយៈការចុះហត្ថលេខាលើអនុសារណៈដែលចែងតួនាទីជាក់លាក់របស់អង្គភាពនិមួយៗ។

សេចក្តីប្រកាសនោះសង្កត់ធ្ងន់លើសេចក្តីត្រូវការរបៀបរបបប្រចាំដំបន់មួយក្នុងការទប់ស្កាត់កុំឲ្យមានការជួញដូរ រួមទាំងការចាត់វិធានការណ៍ការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះពីការជួញដូរ។[39] គំនិតផ្តួចផ្តើមរួមថ្នាក់រដ្ឋមន្ត្រីប្រចាំអនុតំបន់វិសាលភាពមេគង្គប្រឆាំងការជួញដូរ (COMMIT (Coordinated Mekong Ministerial Initiative against Trafficking)) បានបង្កើតឡើងនាឆ្នាំ២០០៤ ដោយមានការចុះហត្ថលេខាលើអនុសារណៈដែលតម្រូវឲ្យរដ្ឋាភិបាលអនុតំបន់វិសាលភាពមេគង្គធ្វើការសម្របសម្រួលនិងពង្រឹងកម្លាំងប្រឆាំងនឹងការជួញដូរ រួមទាំងក្នុងការការពារ ការធ្វើឲ្យសះស្បើយ និងការបញ្ចូលឲ្យរួមរស់ក្នុងសហគមន៍វិញនៃជនរងគ្រោះ។[40] ក្រោមកម្មវិធី COMMIT រដ្ឋាភិបាលជាហត្ថលេខីធ្វើការប្តេជ្ញាក្នុងការធ្វើការសហការប្រឆាំងនឹងការជួញដូរមនុស្សតាមស្តង់ដាអន្តរជាតិ។ ក្រុមការងារជាតិដែលមានមន្ត្រីរដ្ឋាភិបាលពីក្រសួងពាក់ព័ន្ធ (រួមទាំងប៉ូលិស យុត្តិធម៌ សង្គមកិច្ច និងកិច្ចការនារី) ធ្វើសេចក្តីសម្រេចលើគោលនយោបាយប្រឆាំងការជួញដូរមនុស្សនិងការបង្កើតកម្មវិធីក្នុងប្រទេសរបស់ខ្លួនដែលមានការឆ្លុះបង្ហាញជារៀងរាល់ឆ្នាំក្នុងផែនការការងាររបស់ COMMIT និងផែនការអនុវត្តដែលអនុវត្តក្នុងប្រទេស និងរវាងប្រទេសជាទ្វេភាគីនិងពហុភាគីតាមរយៈការធ្វើជាដៃគូរវាងក្រសួងរដ្ឋនិងអង្គភាពក្រៅរដ្ឋាភិបាល រួមទាំងភ្នាក់ងារអង្គការសហប្រជាជាតិ IOM សង្គមស៊ីវិលនិងអង្គភាពដទៃៗទៀត។[41]

ឧទាហរណ៍មួយទៀតអំពីការប្តេជ្ញាពង្រឹងការសម្របសម្រួលក្នុងដំបន់ក្នុងកិច្ចការការពារ គឺគេអាចឃើញនៅក្នុងពិធីការអំពីការទប់ស្កាត់និងប្រឆាំងការជួញដូរស្ត្រីនិងកុមារសម្រាប់ពេស្យាចារ របស់សមាគមអាស៊ីខាងត្បូងសម្រាប់ការសហការក្នុងដំបន់ (SAARC)។[42] ក្រោមអនុសញ្ញានេះ ភាគីរដ្ឋនានាប្តេជ្ញាបង្កើត “ផ្ទះសម្រាប់ការពារ”សម្រាប់ជនរងគ្រោះពីការជួញដូរ ហើយផ្តល់សិទ្ធិនិងទទួលស្គាល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការធ្វើដូច្នេះ។

នៅថ្នាក់ជាតិ ការសម្របសម្រួលនយោបាយកើតឡើងច្រើនយ៉ាង រួមទាំងតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងអង្គភាពមិនមែនរដ្ឋាភិបាលដើម្បីសម្របសម្រួលការងារការពាររបស់គេ។ របៀបរបបខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយ ប៉ុន្តែជាទូទៅមានអ្នកសម្របសម្រួលក្នុងប្រទេសម្នាក់ដែលជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ម្នាក់ឬភ្នាក់ងារមួយ ហើយមានគណៈកម្មាធិការឬតុមូលដែលមានតំណាងមានវ័យចាស់ទុំរបស់ភ្នាក់ងាររដ្ឋាភិបាលនិងក្រុមសង្គមស៊ីវិលដែលធ្វើការជាមួយគ្នាដើម្បីបង្កើតគោលនយោបាយជាតិហើយនិងអនុសាសន៍បទដ្ឋាន។



---

[39] ចូរមើល http://www.asean.org/communities/asean-political-security-community/item/asean-declaration-against-trafficking-in-persons-particularly-women-and-children-3

[40] កម្ពុជា ចិន ឡាវ ភូមា ថៃឡង់ និងវៀតណាម

[41] ចូរមើល http://www.no-trafficking.org/commit.html

[42] សមាគមអាស៊ីខាងត្បូងសម្រាប់ការសហការតំបន់ (SAARC) អនុសញ្ញាអំពីការទប់ស្កាត់និងការប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រីនិងកុមារដើម្បីពេស្យាចារ (*Convention on Preventing and Combating Trafficking in Women and Children for Prostitution)* 2002 ហត្ថលេខីមានរួមរដ្ឋាភិបាលនៃបង់ក្លាដេស ប៊ូតាន ឥណ្ឌា ម៉ាល់ឌីវស៍ ណេប៉ាល់ ប៉ាគិស្ថាន និងស្រីលង្កា

## ៣.៣. ការសម្របសម្រួលថ្នាក់ប្រតិបត្តិ

ដោយសារអង្គភាពមួយចំនួនអាចមានការទាក់ទងនឹងការធ្វើយ៉ាងណាឲ្យមានការការពារដល់ជនរងគ្រោះ វាជាការសំខាន់ណាស់ដែលត្រូវមានយន្តការសម្របសម្រួលដើម្បីអនុញ្ញាតិឲ្យសេវាទាំងនោះស៊ីសង្វាក់គ្នានិងមិនជាន់ជើងគ្នាក្នុងការផ្តល់ជំនួយសមស្រប។ ដើម្បីធ្វើឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ប្រតិបត្តិហើយនិងដើម្បីផ្តល់លទ្ធភាពទៅជនរងគ្រោះពីការជួញដូរក្នុងការទទួលសេវាការពារសមស្រប រដ្ឋនានាបានប្រើយន្តការមួយចំនួននៅតាមដំណាក់ៗនៃការការពារជនរងគ្រោះ ។[43] ចាប់ពីដើមទីទៅការគូសវាសឲ្យឃើញអង្គភាពទាំងឡាយ តួនាទីហើយនិងសេវាការពារដែលគេទាំងនោះផ្តល់ ជាការមានប្រយោជន៍។

### តម្រុយ : ប្រតិបត្តយន្តការនៃការសម្របសម្រួល

ការសម្របសម្រួលនៅថ្នាក់ប្រតិបត្តដើម្បីធានាឲ្យមានកាសហការរវាងភ្នាក់ងារនានាជាកត្តាចាំបាច់មុននឹងឈានទៅបានជោគជ័យក្នុងយុទ្ធសាស្រ្តថ្នាក់ជាតិនិងក្រោមជាតិក្នុងការទប់ស្កាត់និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ គំរូនៃការអនុវត្តល្អមានរាប់បញ្ចូលបែបបទប្រតិបត្តជាស្តង់ដាការប្រជុំជាប្រក្រដីហើយនិងយន្តការនៃការវាយតម្លៃនិងតាមដានដែលអង្គភាពមានតួនាទីទាំងឡាយបានឯកភាពគ្នាហើយនិងបានប្រើ។

យន្តការនៃការសម្របសម្រួលរវាងអង្គភាពរដ្ឋនិងមិនមែនរដ្ឋជា " ក្របខ័ណ្ឌនៃការសហការដែលអង្គភាពរដ្ឋទាំងឡាយប្រើដើម្បីបំពេញកាតព្វកិច្ចរបស់គេក្នុងការការពារនិងលើកដំកើងសិទ្ធិរបស់ជនដែលត្រូវបានគេជួញដូរ ដោយមានការសម្របសម្រួលការងាររបស់គេតាមយុទ្ធសាស្រ្តជាដៃគូជាមួយសង្គមស៊ីវិល។"44 ទោះបីការប្តេជ្ញាថ្នាក់នយោបាយផ្តល់ក្របខ័ណ្ឌសម្រាប់ពង្រឹងការការពារ មធ្យោបាយរួមមួយសម្រាប់ប្រតិបត្តការប្តេជ្ញាទាំងនោះគឺដោយដាក់ការសម្របសម្រួលរវាងអង្គភាពរដ្ឋនិងមិនមែនរដ្ឋឲ្យទៅជាផ្លូវការដើម្បីផ្តល់លទ្ធភាពដល់ជនរងគ្រោះពីការជួញដូរក្នុងការទទួលបានសេវាជំនួយនិងការពារ។ ការដាក់ផ្តុំអ្នកផ្តល់សេវាទាំងឡាយជាមួយគ្នាបែបនេះនឹងធ្វើឲ្យការអនុវត្តច្បាប់ គោលនយោបាយនិងបែបបទនានាទាក់ទងនឹងការការពារបានប្រសើរឡើង។

យន្តការនៃការសម្របសម្រួលក៏អនុញ្ញាតិឲ្យមានការផ្តល់ពត៌មានឲ្យគ្នាទៅវិញទៅមកស្តីអំពីរបៀបអនុវត្តដែលប្រសើរបំផុតក្នុងកិច្ច ការពារផ្តល់ដោយពហុអង្គភាព។ យន្តការទាំងនោះអាចគាំទ្រការសហការទ្វេភាគី ក្នុងតំបន់ និងអន្តរជាតិក្នុងការការពារដោយអនុញ្ញាតិឲ្យអង្គភាពនានានៅក្រោមយុត្តាធិការមួយទាក់ទងធ្វើការប្រកបដោយប្រសិទ្ធិភាពជាមួយអង្គភាពប្រឆាំងការជួញដូរក្រោមយុត្តាធិការដទៃទៀត។ យន្តការទាំងនេះមិនមែនប្រើសម្រាប់តែជាឧបករណ៍សម្រាប់ការសើបអង្កេតនិងផ្តន្ទាទោសទេ ប៉ុន្តែសំដៅជាបឋមលើការការពារជនរងគ្រោះពីការជួញដូរ។45

យន្តការនៃការសម្របសម្រួលដែលមានប្រសិទ្ធិភាពមានវិសាលភាពធំគ្រប់គ្រាន់ដើម្បីចាប់បានការកេងប្រវ័ញ្ចគ្រប់ទ្រង់ទ្រាយ (រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទនិងពលកម្ម ហើយនិងទ្រង់ទ្រាយដទៃទៀតដូចជាការយកសរីរាង្គចេញជាដើម) ប្រភេទនៃជនរងគ្រោះ (រួមទាំងបុរសនិងកុមារាក៏ដូចជាស្រ្តីនិងកុមារី) និងប្រភេទនៃការជួញដូរ(រួមទាំងការជួញដូរក្នុងស្រុកនិងអន្តរជាតិ)។ យន្តការនៃការសម្របសម្រួលដែលមានប្រសិទ្ធិភាពត្រូវមានការចែងឲ្យបានច្បាស់អំពីតួនាទីរបស់ភ្នាក់ងារពាក់ព័ន្ធទាំងឡាយ រួមទាំងការដឹកនាំនិងការទទួលខុសត្រូវ។

គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកវិស័យជួញដូរមនុស្សអាចជាយន្តការសម្របសម្រួលល្អមួយ ដោយធ្វើឲ្យមានការជួបគ្នារវាងតំណាងនៃយុត្តិធម៌ព្រហ្មទ័ណ្ឌ ការងារ អន្តោប្រវេសន៍ ពលកម្មនិងឧស្សាហកម្ម សង្គមកិច្ច ហើយនិងផ្នែកដទៃៗទៀតនៃរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីតាមដានការអនុវត្តយុទ្ធសាស្រ្តជាតិនិងដោះស្រាយបញ្ហានានាដែលលេចឡើងក្នុងក្រសួងនានារបស់រដ្ឋាភិបាល។ កិច្ចប្រជុំថ្នាក់ជាតិអាចធ្វើឡើងដើម្បីបានជាយន្តការពិគ្រោះជាផ្លូវការរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល សហជីពនិងអ្នកមានតួនាទីក្នុងឧស្សាហកម្ម។ ក្រុមការងារក៏អាចត្រូវបង្កើតដើម្បីដោះស្រាយបញ្ហាជួញដូរជាក់លាក់មួយចំនួន ឬដើម្បីដោះស្រាយបញ្ហាប្រតិបត្តក្នុងករណីនិមួយៗ។

---

43 ការប្រតិបត្តកិច្ចសហការអន្តរជាតិរវាងរដ្ឋនិងរដ្ឋក្នុងវិស័យនៃការជួញដូរមនុស្ស ចូរមើលកូនសៀវភៅរបស់អាស៊ានស្តីអំពីការសហការអន្តរជាតិក្នុងវិស័យច្បាប់ស្តីអំពីករណីជួញដូរមនុស្ស *ASEAN Handbook on International Legal Cooperation in Trafficking in Persons Cases)* លេខាធិការដ្ឋានអាស៊ាន ខែសីហា ឆ្នាំ ២០១០

44 យន្តការជាតិនៃការបញ្ជូនឈ្មោះ រួមកម្លាំងដើម្បីការពារសិទ្ធិរបស់ជនដែលគេជួញដូរ (*National Referral Mechanisms, Joining efforts to protect the Rights of Trafficked Persons: A Practical Handbook)* កូនសៀវភៅសម្រាប់អនុវត្ត OSCE/ODIHR ឆ្នាំ ២០០៤ ទំព័រ ១៥

45 ចូរមើល ការជួញដូរមនុស្ស : ការបញ្ចេញមតិរួមអំពីទឹសដៅរបស់សភាហពអឺរ៉ុប របៀបរបបយកសិទ្ធិមនុស្សជាគោល (*Human Trafficking: Joint UN Commentary on the EU Direction - A Human Rights-based Approach*) OHCHR/UNHCR/UNICEF/ UNODC/UN ស្រ្តីនិង អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០១១ ទំព័រ ៥០ និងការអភិវឌ្ឍន៍ NRM បច្ចុប្បន្នក្នុងដំបន់ OSCE (Current NRM Developments in the OSCE Region) ODIHR, ឆ្នាំ ២០០៨

## ការប្រតិបត្តការប្ដេជ្ញានយោបាយដើម្បីពង្រឹងការសម្របសម្រួលក្នុងការការពារជនរងគ្រោះពីការជួញដូរ

ការប្ដេជ្ញានយោបាយប្រកបដោយប្រសិទ្ធិភាព(រួមទាំងអនុសារណៈ) មានរៀបរាប់ផ្នែកសំខាន់ៗមួយចំនួនរួមទាំង ៖

- **ភាគី**នៃការប្ដេជ្ញា **ភារកិច្ច**របស់គេ និងកន្លែងគេត្រូវអនុវត្ត
- **គោលការណ៍និងគោលបំណង**មូលដ្ឋានក្នុងការធ្វើការសហការ
- **ក្រុមអ្នកដែលគេសំដៅ**ឲ្យទទួលផលប្រយោជន៍ពីការប្ដេជ្ញាចិត្ត
- ការចាត់ចែងឲ្យមានទំនាក់ទំនងនិងការផ្ដល់ពត៌មានទៅវិញទៅមកប្រកបដោយសុវត្ថិភាពនិងមានការរក្សាពត៌មានឲ្យនៅសម្ងាត់
- បែបបទសម្រាប់**ការសហការ**
- វិធានការណ៍សមស្របសម្រាប់កុមារ

តាមជាក់ស្ដែង ការប្រតិបត្តសេចក្ដីប្ដេជ្ញានយោបាយគឺប្រព្រឹត្តឡើងដោយភាគីទាំងឡាយក្នុងសេចក្ដីប្ដេជ្ញានោះធ្វើសកម្មភាពទាំងឡាយខាងក្រោមនេះដើម្បីការពារជនរងគ្រោះពីការជួញដូរ ៖

- ការប្ដេជ្ញានយោបាយត្រូវបានគាំទ្រដោយការប្ដេជ្ញាថវិកាគ្រប់គ្រាន់ជនដែលសង្ស័យថាជាជនរងគ្រោះពីការជួញដូរត្រូវគិតថាជាជនរងគ្រោះពីឧក្រិដ្ឋកម្មសម្រាប់គោលបំណងនៃការផ្ដល់ជំនួយនិងការការពារដោយមិនបាច់គិតអំពីឋានៈអន្តោប្រវេសន៍ឬក៏ថាជននោះមានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជាលទ្ធផលនៃការជួញដូរ។
- ជនដែលសង្ស័យថាជាជនរងគ្រោះពីការជួញដូរត្រូវគិតថាជាជនរងគ្រោះពីឧក្រិដ្ឋកម្មសម្រាប់គោលបំណងនៃការផ្ដល់ជំនួយនិងការការពារដោយមិនបាច់គិតអំពីឋានៈអន្តោប្រវេសន៍ឬក៏ថាជននោះមានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជាលទ្ធផលនៃការជួញដូរ។
- ជនសន្មតថារងគ្រោះពីការជួញដូរត្រូវបានប្រាប់ផ្ទាល់មាត់និងជាលាយលក្ខណ៍អក្សរតាមភាសាដែលគេយល់អំពីឱកាសដែលគេអាចទទួលការការពារនិងការគាំទ្រ។
- ជនសន្មតថារងគ្រោះត្រូវទទួលបានឱកាសពិចារណា។
- កន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាពនិងសេវាគាំទ្រចាំបាច់នានាត្រូវមានផ្ដល់ឲ្យជនរងគ្រោះដោយមិនបាច់គិតអំពីឋានៈអន្តោប្រវេសន៍ឬការស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តរបស់គេក្នុងការចូលរួមក្នុងពិធីសើបអង្កេតឧក្រិដ្ឋកម្ម។
- ដៃគូក្នុងវិស័យការពារដែលជាអង្គភាពរដ្ឋឬអង្គការក្រៅរដ្ឋាភិបាល ពិគ្រោះគ្នាអំពីការការពារជនដែលសម្រេចធ្វើការសហការជាមួយអាជ្ញាធររកយុត្តិធម៌ក្នុងរឿងឧក្រិដ្ឋកម្ម ឬដែលសម្រេចចង់វិលទៅប្រទេសដើមខ្លួនវិញ។
- ដៃគូដែលជាអង្គភាពរដ្ឋឬអង្គការក្រៅរដ្ឋាភិបាល ពិគ្រោះគ្នាថាតើជនរងគ្រោះពីការជួញដូរប្រឈមគ្រោះថ្នាក់បង្កដោយអ្នកជួញដូរឬទេ។
- ជនសន្មតថារងគ្រោះពីការជួញដូរត្រូវបានប្រាប់ផ្ទាល់មាត់និងជាលាយលក្ខណ៍អក្សរតាមភាសាដែលគេយល់អំពីកម្មវិធីនៃបណ្ដឹងក្នុងអនាគត។
- ជនសន្មតថារងគ្រោះពីការជួញដូរត្រូវមានអមដោយអ្នកផ្ដល់សេវាមុន ក្នុងពេល និងក្រោយពីដំណើរការបណ្ដឹងរកយុត្តិធម៌។
- ជនរងគ្រោះពីការជួញដូរទទួលការគាំទ្រក្នុងការរកសំណង ថវិកាឧបត្ថម ឬសំណងដែលជាការទទួលស្គាល់របួសការបាត់បង់ ឬការខូចខាតដែលខ្លួនបានរង។
- សេចក្ដីត្រូវការរបស់ជនរងគ្រោះក្នុងវិស័យការពារត្រូវបានគិតក្រោយពីពិធីបណ្ដឹងបានចប់ ដើម្បីគាំទ្រកម្មវិធីរួមរស់ក្នុងសង្គមឡើងវិញដែលប្រកបដោយចីរភាពហើយនិងកាត់បន្ថយហានិភ័យនៃការសងសឹកនិងការធ្លាក់ចូលក្នុងការជួញដូរឡើងវិញ។

# ផ្នែកទី៤:

## ការប្រមូលផ្តុំតម្រុយសម្រាប់ការពារជនរងគ្រោះពីការជួញដូរ

✓ **ធ្វើតាមគោលការណ៍សំខាន់ៗសម្រាប់ការពារជនរងគ្រោះពីការជួញដូរ**

- មិនគួរឃុំឃាំង ចោទប្រកាន់ ឬផ្តន្ទាទោស ចំពោះការចូលក្នុងរដ្ឋឬការគ្រឡប់ចូលក្នុងរដ្ឋដោយមិនប្រក្រតី ឬការប្រព្រឹត្តល្មើសច្បាប់មេទៀតៗដែលជាលទ្ធផលផ្ទាល់អំពីការដែលគេត្រូវបានគេជួញដូរ។
- ជនរងគ្រោះគួរមានលទ្ធភាពទទួលការមើលថែផ្លូវកាយនិងផ្លូវចិត្តគ្រប់គ្រាន់។
- ជនរងគ្រោះគួរទទួលបាននូវជំនួយផ្លូវច្បាប់និងជំនួយផ្សេងៗទៀតក្នុងកម្មវិធីបណ្តឹងព្រហ្មទ័ណ្ឌ រដ្ឋប្បវេណី ឬប្រភេទផ្សេងទៀត។
- ជនរងគ្រោះពីការជួញដូរជាកុមារគួរទទួលបាននូវជំនួយនិងការការពារសមស្របយោងតាមភាពងាយរងគ្រោះ សិទ្ធិនិងសេចក្តីត្រូវការពិសេសរបស់គេ។
- ជនរងគ្រោះគួរទទួលបានការធានាពីរដ្ឋដែលទទួលយកឬរដ្ឋដើម អំពីសុវត្ថិភាពក្នុងការវិលទៅរដ្ឋនោះ (បើអាចបាន ធ្វើដោយស្ម័គ្រចិត្ត)។
- ជនរងគ្រោះគួរមានលទ្ធភាពទទួលបានកម្មវិធីបកទោសប្រកបដោយប្រសិទ្ធិភាពនិងសមស្រប។

សូមមើលគោលការណ៍និងសេចក្តីណែនាំអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្សដែលជាអនុសាសន៍របស់ការិយាល័យអគ្គស្នងការសិទ្ធិមនុស្ស។

✓ **ដាក់អនុវត្តមាត្រាស្តីអំពីការការពារចែងក្នុងច្បាប់អន្តរជាតិ:** រដ្ឋនានាគួរធ្វើតាមគំរូរបស់រដ្ឋមួយចំនួនដែលធ្វើលើសពីស្តង់ដាអប្បបរមាកំណត់ដោយ ពិធីការនៃការជួញដូរមនុស្ស ឧទាហរណ៍ ការបញ្ចូលកម្មវិធីផ្តល់សំណងចំពោះការខូចខាតបន្ថែមទៅលើនិងនៅក្រៅកម្មវិធីបណ្តឹងព្រហ្មទ័ណ្ឌ។

✓ **ធ្វើយ៉ាងណាឲ្យបែបបទនៃការការពារដាក់ជនរងគ្រោះនៅកណ្តាល:** ធ្វើយ៉ាងណាឲ្យបែបបទនៃការការពារជនរងគ្រោះពីការជួញដូរ ដាក់ជនរងគ្រោះនៅកណ្តាល ដោយមានការគិតអំពីសុវត្ថិភាពរបស់ជនរងគ្រោះនិងក្រុមគ្រួសាររបស់គេ ហើយនិងការរក្សាពត៌មានរបស់គេឲ្យនៅសម្ងាត់។ កម្មវិធីការពារជនរងគ្រោះគួរអនុវត្តជំពោះជនរងគ្រោះពីការជួញដូរគ្រប់រូបដោយមិនរើសអើង ហើយគួរមានភាពទន់ភ្លន់ដែលអាចបត់បែនទៅតាមសេចក្តីត្រូវការរបស់ជនរងគ្រោះម្នាក់ៗរួមទាំងតាមរយៈការសហការប្រកបដោយប្រសិទ្ធិភាពជាមួយអង្គការក្រៅរដ្ឋាភិបាលជំនាញ។

✓ **ការពារជនរងគ្រោះទោះបីគេធ្វើឬមិនធ្វើការសហការក៏ដោយ:** រដ្ឋគួរធ្វើតាមកាតព្វកិច្ចរបស់ខ្លួនដើម្បីការពារជនរងគ្រោះដោយមិនគិតអំពីឋានៈទេសន្តរប្រវេសន៍ឬឋានៈអ្វីផ្សេងទៀតរបស់គេ ហើយនិងតើគេស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មក៏ដោយ។

✓ **ចូរផ្តល់ឱកាសពិចារណាដល់ជនរងគ្រោះពីការជួញដូរ:** ចូរផ្តល់ឱកាសពិចារណាដល់ជនរងគ្រោះពីការជួញដូរដើម្បីឲ្យគេអាចចាប់ផ្តើមសះស្បើយឡើងវិញ។ ឱកាសពិចារណានិងការគាំទ្រនានាដែលពាក់ព័ន្ធ រួមទាំងទិដ្ឋាការបណ្តោះអាសន្នសម្រាប់ជនរងគ្រោះពីការជួញដូរឆ្លងដែន គួរផ្តល់ទៅឲ្យជនរងគ្រោះទោះបីគេស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តចូលរួមក្នុងបណ្តឹងប្រឆាំងនឹងអ្នកជួញដូរក៏ដោយ។

✓ **ការពារជនរងគ្រោះពីការជួញដូរមនុស្សតាមបែបបទដែលប្រសើរបំផុត**
សេចក្ដីណែនាំទី ៦
របស់ការិយាល័យស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស *អនុសាសន៍អំពីគោលការណ៍និងសេចក្ដីណែនាំស្ដីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស* ផ្ដល់ដំបូន្មានថារដ្ឋ និងបើត្រូវ អង្គការអន្តររដ្ឋាភិបាលនិងក្រៅរដ្ឋាភិបាលផងដែរ គួរពិចារណា ៖

- ធ្វើយ៉ាងណាកុំដាក់ជនរងគ្រោះក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ឬប្រភេទដទៃ
- ធ្វើយ៉ាងណាកុំបង្ខំជនរងគ្រោះឲ្យទទួលសេវាការពារឬជំនួយដែលគេមិនឯកភាពទទួល
- ផ្ដល់ពត៌មានទៅជនរងគ្រោះអំពីសិទ្ធិរបស់គេក្នុងការទាក់ទងជាមួយតំណាងស្ថានទូតឬកុងស៊ុលរបស់រដ្ឋនៃសញ្ជាតិរបស់គេ
- ការពារជនរងគ្រោះអំពីការគំរាម បង្កគ្រោះថ្នាក់ ឬការសងសឹកពីអ្នកជួញដូរ រួមទាំងដោយរក្សាពត៌មានសម្ងាត់និងអត្តសញ្ញាណរបស់គេ

✓ **ធ្វើការវាយតម្លៃហានិភ័យនៅគ្រប់ដំណាក់ការនៃកម្មវិធីរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្ម** សេចក្ដីត្រូវការរបស់ជនរងគ្រោះក្នុងវិស័យការពារមានភាពខុសគ្នានៅពេលមុន ក្នុង និងក្រោយកម្មវិធីកាត់ទោស។ ដូច្នេះហើយ វិធីប្រសើរបំផុតគឺរដ្ឋធ្វើការវាយតម្លៃហានិភ័យនៅដំណាក់និមួយៗនៃកម្មវិធីនោះដើម្បីធានាឲ្យសេវាការពារផ្ដល់ដល់ជនរងគ្រោះមានការផ្លាស់ប្ដូរត្រូវទៅតាមសេចក្ដីត្រូវការដែលប្រែប្រួល។

✓ **ផ្ដល់ការគាំទ្រមុនពេលកាត់សេចក្ដីដល់ជនរងគ្រោះនិងសាក្សីនៃការជួញដូរមនុស្ស** ប្រការស្ដីអំពីការការពារចែងក្នុងពិធីការនៃការជួញដូរមនុស្ស មានចែងអំពីស្តង់ដាអប្បបរមានៃការគាំទ្រដល់ជនរងគ្រោះនិងសាក្សីនៃការជួញដូរមនុស្ស។ រដ្ឋនានាគួរដាក់អនុវត្តនីតិវិធីផ្លូវការមួយសម្រាប់ផ្ដល់ជំនួយទាំងនោះ។ អង្គការក្រៅរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលដែលស្ទាត់ជំនាញនិងយល់អំពីរបៀបរបបប្រើក្នុងការកាត់សេចក្ដីក្នុងរឿងឧក្រិដ្ឋកម្ម ហើយធ្លាប់មានការហាត់រៀនជំនាញក្នុងការផ្ដល់ជំនួយដល់ជនរងគ្រោះ អាចជួយក្នុងការផ្ដល់សេវាជំនួយទាំងនោះ។

✓ **គាំទ្រជនរងគ្រោះនៅគ្រប់ជំហាននៃការរកយុត្តិធម៌ក្នុងឧក្រិដ្ឋកម្មតាំងពីដើមដល់ចប** រដ្ឋគួរផ្ដល់ដល់ជនរងគ្រោះនូវពត៌មានពេញលេញ ក្នុងភាសាដែលជនរងគ្រោះយល់ អំពីជម្រើសទាំងឡាយដែលគេអាចជ្រើសយករួមទាំងការធ្វើជាសាក្សីក្នុងតុលាការ។ រដ្ឋក៏គួរព្យាយាមផ្ដល់លទ្ធភាពដល់ជនរងគ្រោះក្នុងការទទួលសេវាពិគ្រោះនិងផ្ដល់យោបល់ដើម្បីជួយឲ្យគេយល់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់គេ។

✓ **ដាក់វិធានការណ៍ការពារសម្រាប់ជនរងគ្រោះនិងសាក្សីនៃការជួញដូរជាកុមារ:** រដ្ឋអាចពិចារណាបង្កើតវិធានការណ៍និងឧបករណ៍ជំនួយសាក្សីសម្រាប់ការពារជនងាយរងគ្រោះ ឲ្យមានដោយស្វ័យប្រវត្តសម្រាប់ជនរងគ្រោះជាកុមារ។ វិធីការពារបន្ថែមទៀតដែលអាចពិចារណាមានដូចជាការអនុញ្ញាតិឲ្យយកការថតវីដេអូនៃកិច្ចសម្ភាសន៍របស់ប៉ូលិសជាមួយជនរងគ្រោះជាកុមារ និង/ឬជាមួយសាក្សី ធ្វើជាភស្តុតាងរបស់ខ្លួន។ ប៉ុន្តែជនរងគ្រោះជាកុមារមិនគួរតម្រូវឲ្យចូលរួមទេ ជាពិសេសបើគេបានឆ្លងកាត់ភាពស្លុតរន្ធត់។

✓ **ធ្វើយ៉ាងណាកុំឲ្យកម្មវិធីជំនួយនិងការពារជាការជម្រុញឲ្យចូលរួម:** គួរផ្ដល់កម្មវិធីជំនួយនិងការពារយ៉ាងណាកុំឲ្យក្លាយជាការបង្ខំ ដែលអាចធ្វើឲ្យខូចកម្មវិធីបណ្ដឹង។ អ្វីៗផ្ដល់ឲ្យសាក្សី ឧទាហរណ៍ រួមទាំងកន្លែងស្នាក់នៅ ទិដ្ឋាការ គួរមានការកត់ត្រាទុកនិងមានការពិចារណាថាសមរម្យ ហើយការធ្វើបំពានខុសទាក់ទងនឹងកម្មវិធីគាំពារ ត្រូវកត់សំគាល់ហើយនិងដោះស្រាយជាបន្ទាន់។

- ✓ **ផ្តល់សំណងដែលមានប្រសិទ្ធិភាពសម្រាប់ជាផ្នែកមួយនៃដំណោះស្រាយប្រកបដោយចីរភាពក្នុងការការពារៈ** រដ្ឋនានាគួរពិចារណាបង្កើតប្រភពនៃប្រាក់សំណងសម្រាប់ជនរងគ្រោះពីការជួញដូរក្រៅពីតាមរយៈបណ្តឹងព្រហ្មទ័ណ្ឌ។ គួរធ្វើការពិចារណាធ្វើយ៉ាងណាឲ្យជនរងគ្រោះដែលមិនមានសញ្ជាតិមានលទ្ធភាពទទួលបានសំណងផង។

- ✓ **ធ្វើយន្តការសម្របសម្រួលជាតិសម្រាប់ការពារជនរងគ្រោះពីការជួញដូរឲ្យទៅជាផ្លូវការ** យន្តការសម្របសម្រួលជាតិអាចមានប្រសិទ្ធិភាពជាងបើមានកិច្ចព្រមព្រៀងជាផ្លូវការ ឧទាហរណ៍ តាមរយៈការចុះហត្ថលេខាលើអនុសារណៈដែលចែងតួនាទីជាក់លាក់របស់អង្គភាពនិមួយៗ។

- ✓ **ប្រតិប័ត្តយន្តការនៃការសម្របសម្រួល** ការសម្របសម្រួលនៅថ្នាក់ប្រតិប័ត្តដើម្បីជានាឲ្យមានការសហការរវាងភ្នាក់ងារនានាជាកត្តាចាំបាច់មុននឹងឈានទៅបានជោគជ័យក្នុងយុទ្ធសាស្រ្តថ្នាក់ជាតិនិងក្រោមជាតិក្នុងការទប់ស្កាត់និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ គំរូនៃការអនុវត្តល្អមានរាប់បញ្ចូលបែបបទប្រតិប័ត្តជាស្តង់ដា ការប្រជុំជាប្រក្រតីហើយនិងយន្តការនៃការវាយតម្លៃនិងតាមដានដែលអង្គភាពមានតួនាទីទាំងឡាយបានឯកភាពហើយនិងប្រើ។




REGIONAL SUPPORT OFFICE
THE BALI PROCESS

ទំនាក់ទំនង

Regional Support Office - The Bali Process
27th Floor Rajanakarn Building
3 South Sathorn Road, Sathorn Bangkok 10120, THAILAND
ទូរស័ព្ទ +66 2 343 9477  ទូរសារ +66 2 676 7337
info@rso.baliprocess.net

The Bali **Process**

on People Smuggling, Trafficking in Persons and Related Transnational Crime

http://www.baliprocess.net